Reçu le 7-3-50
INDOCHINE FRANÇAISE RÉGIE DU DÉPÔT LÉGAL

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និង អក្សរសាស្ត្រ បោះពុម្ពផ្សាយ
អំពីពុទ្ធសាសនបណ្ឌិត្យ

---

បណ្ណាធិការ ផ្នែកអក្សរសាស្ត្រ: លោក វ៉ាយ-ប៊ុក ក្រមការ
នៅពុទ្ធសាសនបណ្ឌិត្យ

បណ្ណាធិការ ផ្នែកដំណឹងសាសនា: ព្រះទេពសត្ថា សួរ-ហាយ
ក្រុមជំនុំព្រះត្រៃបិដក នៅពុទ្ធសាសនបណ្ឌិត្យ

---

## បញ្ជីរឿង

| ផ្នែកអក្សរសាស្ត្រ | | ទំព័រ |
|---|---|---|
| ពុទ្ធសាសនបណ្ឌិត្យ | ជូនពរស័ព្ទសាធុការឆ្នាំថ្មី | ១ |
| — | សេចក្ដីជូនដំណឹងអំពីពុទ្ធសាសនបណ្ឌិត្យ រឿងទស្សនាវដ្ដីកម្ពុជសុរិយា ឆ្នាំ ១៩៥០ | ២ |
| លោក វ៉ាយ-ប៊ុក ក្រមការ | ច្បាប់ទូន្មានកុមារា កុមារី | ៥ |
| ហ្លួងនិពន្ធមន្ត្រី ញ៉ុក-ថែម | ការងារជាបច្ច័យញ៉ាំងលោកឲ្យចំរើន | ១១ |
| ឃុនបរិរក្សបរិភ័ណ្ឌ ឈឹម-ណាក | រឿងក្មេងកំព្រា (រឿងពិត) | ២៨ |
| លោក សាង-សាភ័ត | | |
| លេខានុការ ក្រសួងហិរញ្ញវត្ថុ | រឿងព្រេងភូមា | ៣៩ |

| ផ្នែកសាសនា | | |
|---|---|---|
| លោក ម៉ុញ-ផាត្រី តំណាងរាស្ត្រ | ពុទ្ធសាសនានឹងពាហិរសាសនា | ៤៣ |
| ហ្លួងនិពន្ធមន្ត្រី ញ៉ុក-ថែម | ដំណឹងពុទ្ធសាសនាក្នុងនានាប្រទេស | ៥២ |

---

ឆ្នាំទី ២២ — លេខ ១ ខែមករា ឆ្នាំ ១៩៥០ — ថ្លៃជាវ ១ ឆ្នាំ ១៤៥ រៀល ។

Janvier

# ពុទ្ធសាសនា នឹង ពាហិរសាសនា

លោកម៉ុញ - នាគ្រី តំណាងក្រសួង រៀបរៀង

---

## អាទិកថា

ដំណើរដើមដែលនាំឲ្យកើតជាសៀវភៅនេះឡើង ដោយហេតុដែលខ្ញុំបានទៅធ្វើមេប្រយោគប្រឡងសិស្សចេញពីសាលាបាលីរងរៀនកល់ឆ្នាំ ហើយច្រើនត្រូវមុខសួរអំពីរឿងសាសនាចំពោះសិស្សទាំងឡាយ ។ ពេលដែលសួរម្តងៗ អ្នកប្រឡងច្រើនតែទើសទាល់ ឆ្លើយមិនសូវបានហូរហែទូលាយសេចក្តីងាយស្តាប់សោះ ។ រឿងនេះជាហេតុនាំឲ្យខ្ញុំនឹកគួបទុកក្នុងចិត្តថាថ្ងៃណាមួយនឹងធ្វើសៀវភៅនេះឲ្យកើតឡើង ដើម្បីជាផ្លូវងាយស្រួលសិក្សានៃពួកសិក្ខាកាម បំបាត់ការទទាក់ទទាមក្នុងរឿងនេះចេញ ។

ក្នុងការធ្វើសៀវភៅនេះ ផ្នែកខាងពុទ្ធសាសនាខ្ញុំស្រង់មកអំពីគម្ពីរបឋមសាមន្តបាសាទិកា ព្រមទាំងន័យដទៃទៀតខ្លះ, ចំណែកខាងពាហិរសាសនា, ខ្ញុំបានដកស្រង់មកអំពីច្បាប់ផ្សេងៗ ជាភាសាបាលីខ្លះ, បារាំងខ្លះ, សៀមខ្លះ រួបរួមគ្នាកើតជាសៀវភៅនេះឡើង ។

លុះរៀបរៀងចប់ហើយ ខ្ញុំបានយកទៅជូនពុទ្ធសាសនបណ្ឌិត្យឲ្យជួយបោះពុម្ពផ្សាយ ដើម្បីជាវិជ្ជាសម្បត្តិសំរាប់សិស្សសាលាបាលីផង

សំរាប់សាធារណជនទូទៅផង លោកអ្នកលេខាធិការនៃពុទ្ធសាសនបណ្ឌិត្យក៏បានទទួលដោយសេចក្ដីសោមនស្ស ។

ខ្ញុំសូមអភ័យទោសអំពីពួកបណ្ឌិតជនសូមកុំឲ្យយល់ថា ខ្លួនខ្ញុំអ្នករៀបរៀងលំអៀងទៅតាមអគតិណាមួយឡើយ គឺខ្ញុំតែងតាមលំអានដែលមានមកហើយស្រាប់តាមច្បាប់នោះៗ បើមានសេចក្ដីឃ្លៀងឃ្លាតត្រង់ណា សូមមេត្តាបំពេញឲ្យទានផង ។

ទីបំផុតនេះ, សូមឧទ្ទិសកុសលដែលកើតអំពីសៀវភៅនេះ ជូនទៅបុព្វការីជនទាំងឡាយ និងចែករំលែកដល់សព្វសត្តនិករទូទៅ សូមឲ្យបានសេចក្ដីសុខសំរាន្តសព្វ ៗ កាល ។

សព្វេ សត្តា អវេរា ហោន្តុ

សូមឲ្យសត្វគ្រប់គ្នា កុំបីមានពៀរនឹងគ្នាឡើយ

**វត្តឧណ្ណាលោម ក្រុងភ្នំពេញ**

**ថ្ងៃព្រហស្បតិ៍ ១២ កើត ខែមិគសិរ ឆ្នាំមមែបញ្ចស័ក ព. ស. ២៤៨៦**

**( ថ្ងៃ ៩ ខែដេសំប្រ៊ី ឆ្នាំ ១៩៤៣ )**

**ម. ណាត្រ**

ពុទ្ធសាសនា

# ពាក្យថា សាសនា

ពាក្យទុកទំ ពាក្យទូន្មានប្រៀនប្រដៅរបស់សាស្តាចារ្យណាមួយក្នុងលោក ហៅថា សាសនា ។

សាសនាបើសំដែងដោយប្រភេទជាប្រធាននៃគោលធំៗ មាន ២ គឺ ពុទ្ធសាសនា ១ ពាហិរសាសនា ១ ។

ពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធជាអគ្គបុគ្គល ជាសាស្តាឯកក្នុងលោក ហៅថា ពុទ្ធសាសនា ។ ពាក្យប្រៀនប្រដៅរបស់គណាចារ្យណាមួយដទៃក្រៅចាកព្រះបរមសាស្តា ហៅថា ពាហិរសាសនា ។

ពុទ្ធសាសនាប្រដៅឲ្យជឿហេតុនឹងផល គឺឲ្យកាន់ឲ្យប្រកាន់ថា ហេតុល្អនឹងឲ្យផលល្អ ហេតុអាក្រក់នឹងឲ្យផលអាក្រក់ អ្វីទាំងអស់ក្នុងលោកសុទ្ធសឹងប្រកបដោយហេតុនឹងផល សមដូចជាគាថាដែលព្រះអស្សជិត្ថេរសំដែងកាន់ឡើងថា :

យេ ធម្មា ហេតុប្បភវា តេសំ ហេតុំ តថាគតោ
តេសញ្ច យោ និរោធោ ច ឯវំ វាទី មហាសមណោ

ព្រះតថាគត ទ្រង់ត្រាស់សំដែងនូវធម៌ទាំងឡាយ ដែលជាធម៌មានហេតុជាដែនកើតមុន ទ្រង់ត្រាស់សំដែងនូវសេចក្តីរលត់នឹងឧបាយ

នៃសេចក្ដីលេតខ្វល់ធម៌ទាំងឡាយនោះ ព្រះមហាសមណៈ ទ្រង់មានប្រក្រតីពោលយ៉ាងនេះ ។

មួយទៀត ពុទ្ធសាសនាប្រដៅឲ្យជឿកម្មនិងផលរបស់កម្ម គឺថា កម្មល្អនឹងឲ្យផលល្អ កម្មអាក្រក់នឹងឲ្យផលអាក្រក់; សេចក្ដីល្អ អាក្រក់ សុខទុក្ខ ចំរើនវិនាស មានក្រជាដើម ស្រេចហើយតែអំពើរបស់ខ្លួន ដែលបានធ្វើទុកក្នុងអតីតជាតិ ឬក្នុងជាតិជាបច្ចុប្បន្ន ឥតមានអ្វីជួយឲ្យគេចផុតចាកកម្មនិងផលនៃកម្មទៅបានឡើយ ។

សមដូចព្រះពុទ្ធដីកាសំដែងទុកក្នុងទសធម្មសូត្រថា **កម្មស្សកោម្ហិ** អាត្មាអញមានកម្មជារបស់ខ្លួន **កម្មទាយាទោ** មានកម្មជាទ្រព្យសំបាច់មតក **កម្មយោនិ** មានកម្មជាកំណើត **កម្មពន្ធុ** មានកម្មជាផៅពង្សជាសាច់សន្ដាន **កម្មបដិសរណោ** មានកម្មជាទីពឹងអាស្រ័យ **យំ កម្មំ ករិស្សាមិ កល្យាណំ វា បាបកំ វា** អាត្មាអញនឹងធ្វើនូវអំពើឯណា ទោះជាអំពើល្អក្ដី អាក្រក់ក្ដី **តស្ស ទាយាទោ ភវិស្សាមិ** នឹងបានជាអ្នកទទួលយកផលកម្មនោះប្រាកដពុំខាន ។

ន័យមួយទៀតថា:

អត្តនា វ កតំ បាបំ អត្តនា សំកិលិស្សតិ
អត្តនា អកតំ បាបំ អត្តនា វ វិសុជ្ឈតិ
សុទ្ធិ អសុទ្ធិ បច្ចត្តំ នាញ្ញោ អញ្ញំ វិសោធយេ

អំពើអាក្រក់ដែលខ្លួនឯងធ្វើហើយ នឹងសៅហ្មងដោយខ្លួនឯង អំពើអាក្រក់ដែលខ្លួនមិនបានធ្វើហើយ នឹងបរិសុទ្ធចំពោះខ្លួន សេចក្ដីបរិសុទ្ធ មិនបរិសុទ្ធ ស្រេចលើខ្លួន បុគ្គលដទៃនឹងឲ្យបុគ្គលដទៃបរិសុទ្ធដូចម្ដេចបាន ។

## គោលប្រដៅ ៣ យ៉ាង

ពុទ្ធសាសនា បើសំដែងអំពីគោលនៃការប្រដៅធំៗ មាន ៣ គឺ:

**១– សព្វបាបស្ស អករណំ** កិរិយាមិនធ្វើអំពើអាក្រក់សព្វយ៉ាង ។

**២ - កុសលស្សូបសម្បទា** ការញុំាងកុសលឲ្យសំរេចគឺឲ្យខំធ្វើអំពើល្អ ។

**៣ - សចិត្តបរិយោទបនំ** កិរិយាញុំាងចិត្តរបស់ខ្លួនឲ្យផូរផង់ គឺត្រូវផុសខាត់ចិត្តរបស់ខ្លួនឲ្យបរិសុទ្ធ ។

**ឯតំ ពុទ្ធានសាសនំ** ពាក្យទាំង ៣ យ៉ាងនេះជាពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធគ្រប់ព្រះអង្គ ។

ពុទ្ធោវាទទាំង ៣ ប្រការនេះ បើនឹងរាប់បញ្ចូលទៅក្នុងបិដកទាំង ៣ ត្រង់ពាក្យថា: "មិនឲ្យធ្វើបាបសព្វយ៉ាង" ចាត់ចូលក្នុងវិនយបិដក, ពាក្យថា "ឲ្យខំធ្វើអំពើល្អ" ចាត់ចូលក្នុងសុត្តន្តបិដក, ពាក្យថា "ខំសំអាតចិត្តរបស់ខ្លួនឲ្យផូរផង់" ចាត់ចូលក្នុងអភិធម្មបិដក ។

# ប្រយោជន៍ក្នុងពុទ្ធសាសនា

ពុទ្ធសាសនា បើសំដែងអំពីផលប្រយោជន៍អំពីគុណបំណាច់ម្នាក់ម្រែ រង្គាន់ដែលពុទ្ធសាសនិកជនត្រូវបាន ព្រះពុទ្ធទ្រង់ប្រដៅបំបែកផ្លូវជា ៣ គឺ:

១ – ទិដ្ឋធម្មិកត្ថ = ប្រយោជន៍ក្នុងបច្ចុប្បន្ន

២ – សម្បរាយិកត្ថ = ប្រយោជន៍ក្នុងលោកខាងមុខ

៣ – បរមត្ថ = ប្រយោជន៍ដ៏ឧត្តមគឺព្រះនិព្វាន

ប្រយោជន៍បច្ចុប្បន្ន ចែកចេញជា ៤ ប្រការគឺ:

១ – **ឧដ្ឋានសម្បទា** សេចក្ដីពេញលេញដោយការខ្នះខ្នែង គឺការចំប្រឹងរកទ្រព្យសម្បត្តិ ឲ្យបានមកតាមធម៌ មានវៀរចាកចំនួញ ៥ ប្រការជាដើម ។

២ – **អារក្ខសម្បទា** សេចក្ដីពេញលេញដោយការរក្សា គឺការថែរក្សាទ្រព្យសម្បត្តិដែលបានមកហើយ ឲ្យគង់នៅមិនឲ្យវិនាស ទៅដោយល្បែងពាលផ្សេងៗ មានល្បែងស្រី - ស្រា - ស៊ីសងជាដើម ។

៣ – **កល្យាណមិត្តតា** ភាពនៃបុគ្គលមានមិត្តល្អ គឺវៀរចាកបាបមិត្ត ហើយសេពគប់រកតែកល្យាណមិត្ត ។

៤ – **សមជីវិតា** ភាពនៃបុគ្គលអ្នកចិញ្ចឹមជីវិតស្មើៗ គឺចិញ្ចឹមតាមសមគួរដល់កំឡាំងធនធានរបស់ខ្លួន មិនចាយក៏យខ្ជះខ្ជាយឥតបទឥតសណ្ដាប់ ។

នេះជាប្រយោជន៍សម្រាប់ចែកសេចក្ដីសុខក្នុងបច្ចុប្បន្ន ។

ប្រយោជន៍ក្នុងលោកខាងមុខ ចែកចេញជា ៤ ប្រការ គឺ :

១ — សទ្ធាសម្បទា សេចក្ដីពេញលេញដោយជំនឿ

២ — សីលសម្បទា សេចក្ដីពេញលេញដោយសីល គឺត្រូវរក្សានិច្ចសីល ឧបោសថសីល អតិរេកសីល ចតុប្បារិសុទ្ធិសីល តាមនាទីរបស់ខ្លួន ។

៣ — ចាគសម្បទា សេចក្ដីពេញលេញដោយការចែកទាន គឺចេះចែករំលែកផលទានដែលខ្លួនរកបានមកដោយធម៌ ដល់សមណៈព្រាហ្មណ៍ យាចកអ្នកកំសត់ទុគ៌ត កំព្រីកំព្រា អនាថា តាមសមគួរ ឈ្មោះថាជាគ្រឿងចែកសេចក្ដីសុខដល់អ្នកដទៃ ។

៤ — បញ្ញាសម្បទា សេចក្ដីពេញលេញដោយបញ្ញា គឺប្រកបដោយសេចក្ដីយល់ឃើញជាសម្មាទិដ្ឋិ មានការយល់ឃើញថាធ្វើបុណ្យបានបុណ្យធ្វើបាបបានបាបជាដើម ។

## ប្រភេទរបស់ព្រះពុទ្ធសាសនា

ពុទ្ធវចនៈទាំងអស់នោះ គឺ :

**រសវសេន ឯកវិធំ** មានតែមួយដោយអំណាចនៃវិមុត្តិរស

**ធម្មវិនយវសេន ទុវិធំ** មាន ២ យ៉ាងដោយអំណាចនៃធម៌និងវិន័យ

បឋមមជ្ឈិមបច្ឆិមវសេន តិវិធំ មាន ៣ យ៉ាងដោយបឋម-ពុទ្ធវចនៈ មជ្ឈិមពុទ្ធវចនៈ និងបច្ឆិមពុទ្ធវចនៈ ។

តថា បិដកវសេន មាន ៣ យ៉ាងដោយអំណាចបិដកទាំង ៣

និកាយវសេន បញ្ចវិធំ មាន ៥ យ៉ាងដោយអំណាចនៃនិកាយទាំង ៥

អង្គវសេន នវវិធំ មាន ៩ យ៉ាងដោយអំណាចនៃអង្គទាំង ៩

ធម្មក្ខន្ធវសេន ចតុរាសីតិសហស្សវិធំ មាន ៨៤.០០០ ដោយអំណាចព្រះធម្មក្ខន្ធ ។

## ពុទ្ធវចនៈ ១ យ៉ាង

ពាក្យដែលព្រះដ៏មានព្រះភាគទ្រង់ត្រាស់ប្រៀនប្រដៅសត្វលោក មានទេវតាមនុស្សនាគយក្ខជាដើម បុពមិដែលទ្រង់រំពឹងពិចារណាគន់ រង់ ៤០ វស្សា ចាប់ដើមអំពីថ្ងៃដែលទ្រង់បានត្រាស់ដឹងនូវអនុត្តរសម្មា-សម្ពោធិញ្ញាណ ដរាបដល់ពេលដែលទ្រង់រំលត់ខន្ធចូលកាន់បរិនិព្វាន ដោយអនុបាទិសេសនិព្វានធាតុ ព្រះពុទ្ធវចនៈទាំងអស់នុ៎ះប្រមូលប្រួមមកមានតែមួយ គឺដើម្បីឲ្យសត្វបានត្រេកផឹកនូវវិមុត្តិរសប៉ុណ្ណោះឯង; យ៉ាងនេះឈ្មោះថា ពុទ្ធវចនៈមានតែមួយដោយអំណាចនៃវិមុត្តិរស ។

## ពុទ្ធវចនៈ ២ យ៉ាង

សព្វមេវ ហេតំ ធម្មោ ច វិនយោ ច គឺពុទ្ធវចនៈទាំងអស់ហ្នឹងឯង ប្រមូលមកមានពីរយ៉ាង គឺធម៌ ១ វិន័យ ១ ។

**តត្ថ វិនយបិដកំ វិនយោ** បណ្ដាពុទ្ធវចនៈទាំង ២ នោះ វិនយបិដក ហៅថា វិន័យ, **អវសេសំ ពុទ្ធវចនំ ធម្មោ** ពុទ្ធវចនៈដ៏សេស ក្រៅពីវិន័យ ហៅថា ធម៌ ។

សមដូចពាក្យដែលព្រះមហាកស្សបត្ថេរពោលទុកថា **យន្នូន មយំ អាវុសោ ធម្មញ្ច វិនយញ្ច សង្គាយាម** ម្នាលអាវុសោ បើដូច្នោះ មានតែយើងនឹងសង្គាយនានូវធម៌ផង វិន័យផង ខ្ញុំត្រូវសួរវិន័យចំពោះឧបាលី, ត្រូវសួរធម៌ចំពោះអានន្ទ; យ៉ាងនេះ ដែលឈ្មោះថា ពុទ្ធវចនៈមាន ២ យ៉ាងដោយអំណាចធម៌នឹងវិន័យ ។

## ពុទ្ធវចនៈ ៣ យ៉ាង

**សព្វមេវ ហិទំ បឋមពុទ្ធវចនំ មជ្ឈិមពុទ្ធវចនំ បច្ឆិមពុទ្ធវចនន្តិ តិប្បភេទំ** ពុទ្ធវចនៈទាំងអស់នោះ មានប្រភេទ ៣ គឺ : បឋមពុទ្ធវចនៈ ១ មជ្ឈិមពុទ្ធវចនៈ ១ បច្ឆិមពុទ្ធវចនៈ ១ ។

បណ្ដាពុទ្ធវចនៈទាំង ៣ នេះ ត្រង់ឧទានគាថាដែលព្រះសាស្ដាទ្រង់នឹកភ្ញាក់អស្ចារ្យក្នុងព្រះទ័យលាន់ចេញមកជាព្រះវាចា ក្នុងកាលដែលទើបបានត្រាស់ដឹងថ្មីៗ ថា :

**អនេកជាតិសំសារំ សន្ធាវិស្សំ អនិព្វិសំ**
**គហការំ គវេសន្តោ ទុក្ខា ជាតិ បុនប្បុនំ**
**គហការក ទិដ្ឋោសិ បុន គេហំ ន កាហសិ**

សព្វា តេ ផាសុកា ភគ្គា   គហកូដំ វិសង្ខតំ
វិសង្ខារគតំ ចិត្តំ   តណ្ហានំ ខយមជ្ឈគា ។

តថាគតកាលអន្ទោលទៅមក   ដោយយកកំណើតក្នុងសង្សារវដ្ត អស់ជាតិជាអនេកស្វែងរកជាងផ្ទះគឺតណ្ហា   មិនបានជួបប្រទះសោះឡើយ ម្ល៉ោះហើយជាតិតែងនាំមកនូវសេចក្តីទុក្ខលំបាករឿយៗ, នែជាងផ្ទះ តថា-គតរកអ្នកឃើញហើយ   អ្នកលែងសង់ផ្ទះគឺអត្តភាពឲ្យតថាគតទៀតហើយ (ព្រោះថា) គ្រឿងប្រក់របស់អ្នកតថាគតបោចពេចបំបាក់ចោលអស់រលីងហើយ   ទាំងកំពូលផ្ទះតថាគតកាច់ចោលហើយដែរ ចិត្ត (របស់តថាគត) ផុតស្រឡះចាកការតាក់តែងហើយ   ព្រោះតថាគតបានដល់នូវការអស់ទៅនៃតណ្ហា,   នេះហៅថា   បឋមពុទ្ធវចនៈ ។

ពុទ្ធវចនៈដែលព្រះដ៏មានព្រះភាគទ្រង់ត្រាស់ផ្តាំបំផុតក្នុងកាលទៀបបរិនិព្វានជាអវសានទុកថា: ហន្ទទានិ ភិក្ខវេ អាមន្តយាមិ វោ វយធម្មា សង្ខារា អប្បមាទេន សម្បាទេថ នែភិក្ខុទាំងឡាយ ឥឡូវនេះតថាគតផ្តាំអ្នកពល់គ្នាថា: “ សង្ខារទាំងឡាយរមែងមានសភាពសោះសូន្យទៅជាធម្មតា (ហេតុនេះ) អ្នកពល់គ្នា ចូរញ៉ាំងកិច្ចទាំងពួងឲ្យសំរេច ដោយសេចក្តីមិនប្រហែសធ្វេស ”, នេះហៅថា បច្ឆិមពុទ្ធវចនៈ ។

ពុទ្ធវចនៈទាំងអស់ដែលព្រះដ៏មានព្រះភាគទ្រង់ត្រាស់សំដែងក្នុងកាលជាចន្លោះ   ជាកណ្តាលនៃពុទ្ធវចនៈទាំងពីរ   គឺបឋមពុទ្ធវចនៈនឹងបច្ឆិមពុទ្ធវចនៈ   ហៅថា   មជ្ឈិមពុទ្ធវចនៈ ។

យ៉ាងនេះដែលហៅថាពុទ្ធវចនៈមាន ៣ យ៉ាង ដោយអំណាចពុទ្ធវចនៈជាន់ដំបូង ជាន់កណ្ដាល ជាន់ចុងបំផុត ។

## ពុទ្ធវចនៈ ៣ យ៉ាង បិដក ៣

ពុទ្ធវចនៈទាំងអស់នោះ មានប្រភេទ ៣ គឺវិនយបិដក ១ សុត្តន្តបិដក ១ អភិធម្មបិដក ១ ។

បណ្ដាពុទ្ធវចនៈទាំង ៣ នោះ បាដិមោក្ខទាំង ២ (ភិក្ខុបាដិមោក្ខ ភិក្ខុនីបាដិមោក្ខ) វិភង្គទាំង ២ (ភិក្ខុវិភង្គ ភិក្ខុនីវិភង្គ) ខន្ធក ២២ បរិវារ ១៦ ដែលលោកប្រមូលយកសង្គីតិនិងអនុសង្គីតិទាំងអស់ ក្នុងកាលបឋមសង្គាយនា បើគិតរួមមកជាគម្ពីរមាន ៥ គឺ: អាទិកម្ម, បាចិត្តិយ, មហាវគ្គ, ចូឡវគ្គ, បរិវារ, រួមមកហៅថា វិនយបិដក ។

ធម៌ដែលលោករួបរួមយកសូត្រ ៣៤ មានព្រហ្មជាលសូត្រជាដើម មកឲ្យឈ្មោះថា "ទីឃនិកាយ" ។ ធម៌ដែលលោករួបរួមយកសូត្រ ១៥២ មានមូលបរិយាយសូត្រជាដើមមកឲ្យឈ្មោះថា "មជ្ឈិមនិកាយ" ។ ធម៌ដែលលោករួបរួមយកសូត្រ ៧៧៦២ មានឱឃតរណសូត្រជាដើមមកឲ្យឈ្មោះថា "សំយុត្តនិកាយ" ។ ធម៌ដែលលោករួបរួមយកសូត្រ ៩៥៥៧ មកឲ្យឈ្មោះថា "អង្គុត្តរនិកាយ" ។ ធម៌ដែលមានប្រភេទ ១៥ គឺខុទ្ទកបាឋ, ធម្មបទ, ឧទាន, ឥតិវុត្តក, សុត្តនិបាត, វិមានវត្ថុ, បេតវត្ថុ, ថេរគាថា, ថេរីគាថា, ជាតក, និទ្ទេស, បដិសម្ភិទា, អបទាន, ពុទ្ធវំស, ចរិយាបិដក, មកឲ្យឈ្មោះថា "ខុទ្ទកនិកាយ" ។

ធម្មសង្គណី, វិភង្គ, ធាតុកថា, បុគ្គលប្បញ្ញត្តិ, កថាវត្ថុ, យមក, បដ្ឋាន ហៅថា "អភិធម្មបិដក" ។

បិដកទាំង ៣ នេះ បើចែកតាមដំណើរទេសនាមាន ៣ គឺ អាណា-ទេសនា ១ វោហារទេសនា ១ បរមត្ថទេសនា ១ ។

វិនយបិដក ដែលព្រះដ៏មានព្រះភាគជាបុគ្គលគួរដល់អាជ្ញាត្រាស់សំដែងសម្បូណ៌ដោយអាជ្ញា ហៅថា "អាណាទេសនា" ។ សុត្តន្ត-បិដក ដែលព្រះដ៏មានព្រះភាគជាវោហារកោសល គឺជាបុគ្គលឈ្លាសវៃដោយវោហារថ្វីព្រះទស្សត្រាស់សំដែងសម្បូណ៌ដោយវោហារ ហៅថា "វោហារទេសនា" ។ អភិធម្មបិដក ដែលព្រះដ៏មានព្រះភាគឈ្លាសវៃដោយបរមត្ថត្រាស់សំដែងច្រើនដោយបរមត្ថធម៌ ជាធម៌មានសេចក្តីជ្រាល-ជ្រៅ ហៅថា "បរមត្ថទេសនា" ។

ចែកតាមដំណើរពាក្យសាសនា (ការប្រៀនប្រដៅ) មាន ៣ យ៉ាងគឺ យថាបរាធសាសនា ១ យថានុលោមសាសនា ១ យថាធម្មសាសនា ១ ។

វិនយបិដក ហៅថា យថាបរាធសាសនា (ការប្រៀនប្រដៅតាមកំហុស) ព្រោះថាពួកសត្វដែលមានកំហុស ព្រះអង្គទ្រង់ប្រៀនប្រដៅតាមកំហុស ក្នុងវិនយបិដកនេះ ។ សុត្តន្តបិដក ហៅថា យថានុលោមសាសនា (ការប្រៀនប្រដៅតាមសមគួរ) ព្រោះថាពួកសត្វដែលលង់នៅក្នុងអធ្យាស្រ័យ អនុស័យនិងចរិយាជាអនេក ព្រះអង្គត្រាស់ប្រៀនប្រដៅ

អនុលោមតាមអធ្យាស្រ័យ អនុស័យនិងចរិយានោះៗ ក្នុងសុត្តន្តបិដកនេះ ។ អភិធម្មបិដក ហៅថា យថាធម្មសាសនា (ការប្រៀនប្រដៅតាមធម៌ឬតាមសភាពពិតមែន) ព្រោះថា ពួកសត្វដែលមានសេចក្តីយល់ក្នុងពួកនៃធម៌ថា "ខ្លួនអញ របស់អញ" ព្រះអង្គទ្រង់សំដែងប្រៀនប្រដៅតាមសភាពពិត ក្នុងអភិធម្មបិដកនេះ ។

បើចែកតាម កថា មាន ៣ យ៉ាង គឺ: សំវរាសំវរកថា ១ ទិដ្ឋិវិនិវេឋនកថា ១ នាមរូបបរិច្ឆេទកថា ១ ។

វិនយបិដក ហៅថា សំវរាសំវរកថា ព្រោះការសង្រួមនិងមិនសង្រួមជាសត្រូវដល់អជ្ឈាចារ (សេចក្តីប្រព្រឹត្តល្អត្រឹមត្រូវ) ព្រះអង្គទ្រង់សំដែងទុកក្នុងវិនយបិដកនេះ ។ សុត្តន្តបិដក ហៅថា ទិដ្ឋិវិនិវេឋនកថា ព្រោះជាការដោះចាកទិដ្ឋិ ជាប់ក្នុងពួកនៃទិដ្ឋិ ៦២ ព្រះអង្គទ្រង់ត្រាស់សំដែងទុកក្នុងសុត្តន្តបិដកនេះ ។ អភិធម្មបិដក ហៅថា នាមរូបបរិច្ឆេទកថា ព្រោះការកំណត់នូវនាមនិងរូប ជាសត្រូវដល់កិលេសមានរាគៈជាដើម ព្រះអង្គទ្រង់សំដែងទុកក្នុងអភិធម្មបិដកនេះ ។

បិដកទាំង ៣ នេះ បើចែកតាមសិក្ខា មាន ៣ គឺ អធិសីលសិក្ខា ១ អធិចិត្តសិក្ខា ១ អធិបញ្ញាសិក្ខា ១ ។ វិនយបិដករាប់បញ្ចូលក្នុងអធិសីលសិក្ខា ពីព្រោះការសិក្សាការរៀនយកអធិសីល ព្រះអង្គទ្រង់សំដែងទុក

ដោយសេចក្តីពិសេសពិស្តារក្នុងវិនយបិដក ។ សុត្តន្តបិដក រាប់បញ្ចូលក្នុងអធិចិត្តសិក្ខា ព្រោះថាការសិក្សារៀនយកអធិចិត្ត ព្រះអង្គត្រាស់សំដែងទុកក្នុងសុត្តន្តបិដក ។ អភិធម្មបិដក រាប់បញ្ចូលក្នុងអធិប្បញ្ញាសិក្ខា ព្រោះថាការសិក្សារៀនយកអធិបញ្ញា ព្រះអង្គត្រាស់សំដែងដោយសេចក្តីវិសេសក្នុងអភិធម្មបិដក ។

បើចែកតាមប្រភេទនៃការលះ មាន ៣ គឺ វិតិក្កមប្បហាន ១ បរិយុដ្ឋានប្បហាន ១ អនុស័យប្បហាន ១ ។

វិតិក្កមប្បហាន (ការលះបង់នូវសេចក្តីល្មើស) រាប់បញ្ចូលក្នុងវិនយ-បិដក ព្រោះសីលមានការប្រព្រឹត្តិកន្លងប្រព្រឹត្តល្មើសជាសត្រូវ ។ បរិយុដ្ឋានប្បហាន (ការលះបង់នូវទីតាំងរបស់កិលេស) រាប់បញ្ចូលក្នុងសុត្តន្តបិដក ព្រោះសមាធិមានបរិយុដ្ឋានកិលេសជាសត្រូវ ។ អនុស័យ-ប្បហាន (ការលះបង់នូវអនុស័យកិលេស) រាប់បញ្ចូលក្នុងអភិធម្មបិដក ព្រោះបញ្ញាមានអនុស័យ គឺធម៌ជាគ្រឿងដេកត្រាំក្នុងសន្តានជាសត្រូវ ។ មួយទៀត តទង្គប្បហាន (ការលះបង់នូវអង្គដោយអង្គ) រាប់បញ្ចូលក្នុងវិនយបិដក ។ វិក្ខម្ភនប្បហាន (ការលះបង់នូវកិលេសដោយការសង្កត់សង្កិន) និង សមុច្ឆេទប្បហាន (ការលះបង់ផ្តាច់ផ្តិល) រាប់បញ្ចូលក្នុង សុត្តន្តបិដកនិងអភិធម្មបិដក ។

មួយទៀត ការលះបង់នូវទុច្ចរិតសង្កិលេស រាប់បញ្ចូលក្នុងវិនយ-បិដក, តណ្ហាសង្កិលេសនិងទិដ្ឋិសង្កិលេស រាប់បញ្ចូលក្នុងសុត្តន្តបិដក និងអភិធម្មបិដក ។

ក្នុងបិដកមួយៗ មានគម្ភីរភាពបួនៗ គឺភាពជ្រាលជ្រៅដោយធម៌ ដោយអត្ថ ដោយទេសនា និងដោយបដិវេធ ។ បាលី ហៅថា ធម៌, សេចក្ដីអធិប្បាយរបស់បាលីនោះ ហៅថា អត្ថ, ការសំដែងពន្យល់នូវបាលីនោះ ហៅថា ទេសនា (ព្រោះបាលីជាសទ្ទជាតិដែលបុគ្គលកំណត់ទុកដោយចិត្ត), ការយល់ច្បាស់តាមសេចក្ដីពិតក្នុងបាលីនិងសេចក្ដីរបស់បាលី ហៅថា បដិវេធ ។

បរិយត្តិមាន ៣ យ៉ាង គឺ អលគទ្ទូបរិយត្តិ ១ និត្ថរណបរិយត្តិ ១ ភណ្ឌាគារិកបរិយត្តិ ១ ។

បណ្ដាបរិយត្តិទាំង៣នេះ បរិយត្តិដែលបុគ្គលកាន់យកមិនល្អ គឺរៀនដើម្បីហេតុមានការប្រណាំងប្រជែងជាដើម ហៅថា អលគទ្ទូបរិយត្តិ (បរិយត្តិប្រៀបដោយពស់មានពិស) មានសេចក្ដីប្រៀបដែលព្រះដ៏មានព្រះភាគទ្រង់ត្រាស់ទុកថា: ម្នាលភិក្ខុទាំងឡាយ បុរសអ្នកត្រូវការដោយពស់មានពិស ។ល។ បុរសនោះឃើញនូវពស់មានពិសយ៉ាងធំហើយចាប់នូវពស់នុ៎ះ ត្រង់ព្នេនក្ដី ត្រង់កន្ទុយក្ដី ពស់នោះនឹងងាកត្រឡប់ចឹកបុរសនោះត្រង់ដៃ ឬ ត្រង់ដើមដៃ ឬ ត្រង់អវយវៈតូចធំណាមួយ បុរសនោះ

នឹងដល់នូវសេចក្ដីស្លាប់ ឬ នូវសេចក្ដីទុក្ខទៀបស្លាប់, ដំណើរនោះព្រោះហេតុអ្វី? ម្នាលភិក្ខុទាំងឡាយ ព្រោះតែពស់ដែលខ្លួនចាប់ហើយមិនល្អ មានឧបមាយ៉ាងណាមិញ; ម្នាលភិក្ខុទាំងឡាយ ពួកមោឃបុរសខ្លះក្នុងលោកនេះរៀនយកនូវធម៌ ។ល។ មោឃបុរសនោះរៀននូវធម៌នោះមិនបានពិនិត្យនូវសេចក្ដីរបស់ធម៌នោះដោយបញ្ញា ទាំងធម៌ទាំងឡាយនោះ ក៏មិនគួរដល់ការពិចារណាឃើញដល់ភិក្ខុទាំងឡាយនោះដែលខ្លួនមិនពិចារណានូវសេចក្ដីដោយបញ្ញា ភិក្ខុទាំងឡាយនោះមានតែការនិសង្សត្រឹមតែការប្រណាំងប្រដែងផង មានការនិសង្សគ្រាន់តែរួចចាកពាក្យពោលថាដូច្នេះដូច្នោះផង រៀនយកនូវធម៌ ។ មួយទៀត ភិក្ខុទាំង-ឡាយរៀនយកនូវធម៌ដើម្បីប្រយោជន៍ឯណា ក៏មិនបានសំរេចប្រយោជន៍នោះ ដល់ភិក្ខុទាំងឡាយនោះទេ; ធម៌ដែលភិក្ខុទាំងឡាយនោះរៀនហើយមិនល្អ រមែងប្រព្រឹត្តទៅព្រមដើម្បីមិនជាប្រយោជន៍ នឹងសេចក្ដីទុក្ខអស់កាលអង្វែង; ដំណើរនោះព្រោះហេតុអ្វី? ម្នាលភិក្ខុទាំងឡាយ ព្រោះភាពនៃធម៌ដែលភិក្ខុរៀនមិនល្អហើយ ។

ឯបរិយត្តិឯណា ដែលភិក្ខុកាន់យកល្អហើយ គឺដែលភិក្ខុរៀនដោយបំណងនឹងបំពេញនូវធម្មក្ខន្ធមានសីលក្ខន្ធជាដើម មិនមែនដើម្បីហេតុមានការប្រណាំងប្រដែងជាដើមឡើយ បរិយត្តិនេះ លោកហៅថានិត្ថរណបរិយត្តិ ។

ពាក្យដែលព្រះដ៏មានព្រះភាគពោលទុកថា ធម៌ទាំងឡាយនោះ ដែលភិក្ខុទាំងឡាយនោះកាន់យកល្អហើយ រៀនល្អហើយ តែងប្រព្រឹត្តទៅព្រមដើម្បីប្រយោជន៍និងសេចក្តីសុខ អស់កាលជាអង្វែង; ដំណើរនោះព្រោះហេតុអ្វី? ព្រោះថាធម៌ទាំងឡាយនោះ ភិក្ខុរៀនយកល្អហើយ ៗ

ចំណែកឯព្រះទីណាស្រេត ដែលមានខ្លួនកំណត់បានហើយ មានកិលេសលះបង់ហើយ មានមគ្គចំរើនហើយ មានអកុសលធម៌ដាក់ចុះហើយ មាននិរោធធ្វើឲ្យជាក់ច្បាស់ហើយ លោករៀនយកនូវបរិយត្តិឯណា ដើម្បីប្រយោជន៍រក្សាប្រវេណី ដើម្បីប្រយោជន៍រក្សាវង្សប៉ុណ្ណោះ; បរិយត្តិនោះ ហៅថា ភណ្ឌាគារិកបរិយត្តិ ៗ

## ពុទ្ធវចនៈ ៥ យ៉ាង

ពុទ្ធវចនៈទាំងអស់នោះ ចែកដោយនិកាយ មានប្រភេទ ៥ គឺ ទីឃនិកាយ ១ មជ្ឈិមនិកាយ ១ សំយុត្តនិកាយ ១ អង្គុត្តរនិកាយ ១ ខុទ្ទកនិកាយ ១ ៗ

ព្រះសូត្រ ៣៤សូត្រ មានព្រហ្មជាលសូត្រជាដើម ដែលលោករួបរួមទុកក្នុងវគ្គ ៣ ហៅថា ទីឃនិកាយ ព្រោះជាទីប្រជុំ ជាទីលំនៅនៃក្រុមសូត្រមានប្រមាណវែង ៗ

ព្រះសូត្រ ១៥២ សូត្រ មានមូលបរិយាយសូត្រជាដើម ដែលលោករួបរួមទុកក្នុងវគ្គ ១៥ មានប្រមាណយ៉ាងកណ្ដាល ( មិនវែងពេក មិនខ្លីពេក ) ហៅថា មជ្ឈិមនិកាយ ។

ព្រះសូត្រ ៧៧៦២ សូត្រ មានឱឃតរណសូត្រជាដើម ដែលតាំងទៅដោយអំណាចនៃធម៌មានទេវតាសំយុត្តជាដើម ហៅថា សំយុត្តនិកាយ ។

ព្រះសូត្រ ៩៥៥៧ សូត្រ មានចិត្តបរិយាយទានសូត្រជាដើម ដែលឋិតនៅដោយអំណាចនៃអង្គមួយៗ ដ៏ក្រៃលែង ហៅថា អង្គុត្តរនិកាយ ។

ព្រះពុទ្ធវចនៈដ៏សេស គឺវិនយបិដក អភិធម្មបិដក ទាំងអស់ព្រមទាំងខុទ្ទកបាឋ ដែលមានប្រភេទ ១៥ ដូចបានសំដែងទុកហើយក្នុងខាងដើម លើកលែងតែនិកាយទាំង ៤ មានទីឃនិកាយជាដើមចេញ ហៅថា ខុទ្ទកនិកាយ ។

ព្រះពុទ្ធវចនៈមាន ៥ យ៉ាងដោយអំណាចនិកាយ ៥ ដោយប្រការយ៉ាងនេះឯង ។

## ពុទ្ធវចនៈ ៩ យ៉ាង

សត្ថុមេវ ហិតំ សុត្តំ គេយ្យំ វេយ្យាករណំ គាថា
ឧទានំ ឥតិវុត្តកំ ជាតកំ អព្ភុតធម្មំ វេទល្លំ នវប្បភេទំ

ព្រះពុទ្ធវចនៈទាំងនោះមានប្រភេទ ៩ យ៉ាង គឺ សុត្ត ១ គេយ្យ ១ វេយ្យាករណ ១ គាថា ១ ឧទាន ១ ឥតិវុត្តក ១ ជាតក ១ អព្ភូតធម្ម ១ វេទល្ល ១ ។

បណ្ដាសត្ថុសាសនៈទាំង ៩ ប្រការនោះ ចំណែកខាងឧភតោវិភង្គ (គឺភិក្ខុវិភង្គ ភិក្ខុនីវិភង្គ) និទ្ទេស (ចូឡនិទ្ទេស មហានិទ្ទេស) ខន្ធក ២២ បរិវារ ១៦ ពួកសូត្រមានមង្គលសូត្រ រតនសូត្រ នាលកសូត្រ និងតុវដ្ដកសូត្រជាដើមក្ដី ពាក្យព្រះតថាគត ដែលបាននាមថាសូត្រ ដទៃក្ដី ហៅថា សុត្ត ។

ព្រះសូត្រដែលប្រកបដោយគាថាទាំងអស់ គឺសូត្រដែលមានបាលីកយលាយច្រឡំដោយគាថា ហៅថា គេយ្យ ។

អភិធម្មបិដកទាំងមូលនិងសូត្រដែលឥតមានគាថា ឬក៏ពុទ្ធវចនៈដទៃដែលលោកមិនសង្គ្រោះចូលដោយអង្គទាំង ៨ ហៅថា វេយ្យាករណៈ (ពាក្យបាលីកយ) ។

ធម្មបទ ថេរគាថា ថេរីគាថា និងគាថាសុទ្ធដែលមិនឲ្យឈ្មោះថាសុត្ត ក្នុងសុត្តនិបាត ហៅថា គាថា ។

ពួកព្រះសូត្រ ៨២ ប្រកបដោយគាថាអាស្រ័យសោមនស្សញាណ ហៅថា ឧទាន ។

ក្រុមព្រះសូត្រ ១១០ ដែលប្រព្រឹត្តទៅដោយន័យថា "វុត្តំ ហេតំ ភគវតា ពាក្យនេះពិតជាព្រះដ៏មានព្រះភាគទ្រង់ត្រាស់ទុកហើយ" ហៅថា ឥតិវុត្តក ។

ជាតក ៥៥០ មានអបណ្ណកជាតកជាដើម ហៅថា ជាតក ។

ព្រះសូត្រប្រកបដោយអច្ឆរិយព្ភុតធម៌ទាំងអស់ ដែលប្រព្រឹត្តទៅដោយន័យមានដើមថា "**ចត្តារោមេ ភិក្ខវេ អច្ឆរិយា អព្ភុតធម្មា អានន្ទេ** ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងឡាយ ៤ យ៉ាងនេះ អស្ចារ្យមិនធ្លាប់កើតមាន មាននៅក្នុងអានន្ទ" ហៅថា អព្ភុតធម៌ ។

ពួកសូត្រទាំងអស់ មានចូឡវេទល្លសូត្រ មហាវេទល្លសូត្រ សម្មាទិដ្ឋិសូត្រ សក្កបញ្ហាសូត្រ សង្ខារភាជនីយសូត្រ និងមហាបុណ្ណកសូត្រជាដើម ដែលបុគ្គលបានសួរទទឹងសេចក្តីត្រេកអរកើតហើយ សួរសាកដេញដោលទៀត ហៅថា វេទល្ល ។

ព្រះពុទ្ធវចនៈមាន ៩ ដោយអំណាចនៃអង្គ ៩ ដោយប្រការយ៉ាងនេះ ។

## ពុទ្ធវចនៈ ៨៤.០០០

ព្រះពុទ្ធវចនៈទាំងអស់នោះ មានប្រភេទ ៨៤.០០០ ដោយអំណាចនៃធម្មក្ខន្ធដែលលោកបំភ្លឺទុកយ៉ាងនេះថា:

**ទ្វាសីតិ ពុទ្ធតោ គណ្ហឹ ទ្វេ សហស្សានិ ភិក្ខុតោ**
**ចតុរាសីតិសហស្សានិ យេ មេ ធម្មា បវត្តិនោ**

ព្រះធម៌ឯណាដែលប្រព្រឹត្តទៅក្នុងហឫទ័យនៃខ្ញុំ (ព្រះធម៌នោះ) មាន ៨៤.០០០ គឺព្រះធម៌ ៨២.០០០ ខ្ញុំរៀនយកអំពីព្រះពុទ្ធ, ២.០០០ រៀនអំពីភិក្ខុ ។

បណ្ដាធម្មក្ខន្ធទាំងឡាយនោះ ដែលទឹងកំណត់ដឹងថាជាធម្មក្ខន្ធមួយៗ គឺ ព្រះសូត្រ ដែលអនុសន្ធិតែមួយចាត់ជាធម្មក្ខន្ធ ១, ព្រះសូត្រណា មានអនុសន្ធិច្រើន ការរាប់ធម្មក្ខន្ធក្នុងព្រះសូត្រនោះ ក៏តាមអនុសន្ធិ (ច្រើនដែរ) ។

ក្នុងពួកគាថាពន្ធ លោកកំណត់ការសួរនូវប្រស្នាមួយ ចាត់ជាធម្មក្ខន្ធមួយ, ការវិស្សជ្ជនាមួយ ចាត់ជាធម្មក្ខន្ធមួយ ។

ក្នុងអភិធម្មវិញ លោកកំណត់ការចែកនូវតិកៈ ទុកៈមួយៗ ឬការចែកនូវវារៈចិត្តមួយៗ ចាត់ជាធម្មក្ខន្ធមួយ ។

ក្នុងវិន័យដែលមានវត្ថុ, មាតិកា, បទភាជនីយ, អន្តរាបត្តិ, អាបត្តិ, អនាបត្តិ និងការកំណត់នូវតិកៈ, ធម៌ទាំងនោះ ចំណែកមួយៗ ចាត់ជាធម្មក្ខន្ធមួយៗ ។

ក្នុងបិដកទាំង ៣ នេះ ព្រះសូត្រមាន ២១.០០០ ព្រះធម្មក្ខន្ធ, ព្រះវិន័យមាន ២១.០០០ ព្រះធម្មក្ខន្ធ, ព្រះអភិធម្មមាន ៤២.០០០ ព្រះធម្មក្ខន្ធ រួបរួមជា ៨៤.០០០ ព្រះធម្មក្ខន្ធ ។

ព្រះពុទ្ធវចនៈមាន ៨៤.០០០ ដោយអំណាចនៃធម្មក្ខន្ធ ដោយប្រការយ៉ាងនេះ ។

# បឋមសង្គាយនា

កាលព្រះបរមគ្រូអរហន្តសម្មាសម្ពុទ្ធ ទើបនឹងទ្រង់រលត់ខ័ន្ធចូលកាន់បរិនិព្វានទៅបានរយៈ ៧ ថ្ងៃ កើតមានពាក្យបំរុះបំរែះក្នុងពុទ្ធ-សាសនមណ្ឌលជាហេតុនាំឲ្យពួកអរហន្តរវល់ក្នុងកិច្ចសាសនា ទើបព្រះមហាកស្សបត្ថេរផ្ដើមនាំព្រះអរហន្តទាំងឡាយលើកសង្គាយនា ផ្ទៀងផ្ទាត់ធម្មវិន័យដែលគង់ដាក់ទុកដោយពួក-ក្រុមថានេះព្រះវិន័យ, នេះព្រះសូត្រ, នេះព្រះអភិធម្ម, សំរេចសេចក្ដីថា ធម៌ពិតធម៌មែន ៗ.

កាលធ្វើសង្គាយនាលើកនេះ ព្រះមហាកស្សបជាអ្នកបុច្ឆាព្រះវិនយ-បិដក ចំពោះព្រះឧបាលី, បុច្ឆាព្រះសុត្តន្តបិដកនឹងព្រះអភិធម្មបិដកចំពោះព្រះអានន្ទ ព្រមដោយការកេសង្ឃ សុទ្ធតែជាព្រះអរហន្តបដិសម្ភិទា ៥០០ អង្គ ធ្វើក្នុងសត្តបណ្ណគុហា ទៀបកំវេភារបព៌តក្នុងនគររាជគ្រឹះ មានព្រះបាទអជាតសត្តុ ជាពុទ្ធសាសនូបត្ថម្ភក៍ អស់កាល ៧ ខែទើបសំរេច ៗ

# ទុតិយសង្គាយនា

កាលព្រះអរហន្តទាំង ៥០០ អង្គ មានព្រះមហាកស្សបត្ថេរជាប្រធានបានធ្វើបឋមសង្គាយនារួចស្រេចហើយ ក៏គ្រប់គ្រងរក្សាព្រះពុទ្ធសាសនាតរៀងមកដរាបដល់អស់ព្រះជន្មបរិនិព្វានទៅរៀងព្រះអង្គ ៗ ដល់ព្រះពុទ្ធសាសនកាលកន្លងទៅបាន ១០០ ឆ្នាំ គ្រានោះ ពួកភិក្ខុជាកូនរបស់

អ្នកស្រុកវជ្ជីនាំគ្នាសំដែងវត្ថុដែលខុសពាក្យធម្មវិន័យ ១០ ប្រការថា ជាធម៌ ជាវិន័យ ។

ឯវត្ថុ ១០ ប្រការនោះ គឺ:

១ – កប្បតិ សិង្គិលោណកប្បោ អំបិលដែលដាក់ទុកក្នុងក្អាក់ស្នែង ទុកឲ្យកន្លងកត្រីហើយយកមកឆាន់ជាមួយអាហារបិណ្ឌបាតបាន មិនត្រូវអាបត្តិ ។

២ – កប្បតិ ទ្វង្គុលកប្បោ ព្រះអាទិត្យជ្រេទៅហើយ ប្រមាណពីរធ្នាប់ ក៏គួរនឹងឆាន់របស់ជាយាវកាលិកបាន មិនត្រូវអាបត្តិ ។

៣ – កប្បតិ គាមន្តរកប្បោ ភិក្ខុមានសេចក្តីគិតថាអញនឹងចូលទៅកាន់ស្រុក ក៏ត្រូវឆាន់អនតិរិត្តភោជនបាន មិនត្រូវអាបត្តិ ។

៤ – កប្បតិ អាវាសកប្បោ ទីអាវាសដែលនៅក្នុងសីមាជាមួយគ្នា ភិក្ខុសង្ឃនឹងធ្វើសង្ឃកម្មទាំងពួងផ្សេងគ្នាបាន មិនត្រូវអាបត្តិ ។

៥ – កប្បតិ អនុមតិកប្បោ កាលដែលនឹងធ្វើសង្ឃកម្មទាំងពួងមិនបាច់ចាំឲ្យជុំគ្នាទេ បើមកដល់មុន នឹងធ្វើសង្ឃកម្មមុនបណ្តើរទៅក៏បាន ឥតក្តាស់ទៀយ ។

៦– **កប្បតិ អាចិណ្ណកប្បោ** សេចក្តីប្រតិបត្តិជាប់តែទំនៀមទំលាប់របស់ឧបជ្ឈាយ៍ អាចារ្យ ទោះខុសក្តីត្រូវក្តី សិស្សានុសិស្សទាំងពួងត្រូវប្រតិបត្តិតាមបាន ឥតមានទោស ។

៧– **កប្បតិ អមថិតកប្បោ** ទឹកដោះស្រស់ដែលប្រែចាកភាពដើមហើយ តែមិនទាន់ក្លាយទៅជាទធិឡើយ ភិក្ខុក្រោកចាកទីអង្គុយហើយ ឆាន់ទឹកដោះជាអនតិរិត្តបាន ។

៨– **កប្បតិ ជលោគឹ បាតុំ** តរុណសុរា សុរាដែលគេដាក់គ្រឿងស្រវឹងផ្សំគ្រាំជាមួយគ្នាហើយ តែនៅខ្សោយមិនទាន់ពេញជាទឹកស្រវឹងនៅឡើយ ភិក្ខុឆាន់បាន ។

៩– **កប្បតិ អទសកំ និសីទនំ** សំពត់និសីទនៈមិនបាច់ធ្វើឲ្យមានជាយ ក៏ត្រូវប្រើបាន មិនមានអាបត្តិឡើយ ។

១០– **កប្បតិ ជាតរូបរជតំ** ភិក្ខុគួរទទួលត្រេកអរចំពោះមាសនឹងប្រាក់បាន មិនត្រូវអាបត្តិឡើយ ។

ព្រះយសត្ថេរ បុត្រកាកណ្ឌកព្រាហ្មណ៍ បានជ្រាបការប្រព្រឹត្តដូច្នោះ ក៏សង្វេគព្រះទ័យ គិតបដិសេធ ដកវត្ថុ ១០ ប្រការនោះចោលចេញ ទើបនិមន្តទៅក្រុងវេសាលី ដើម្បីរម្ងាប់អធិករណ៍នោះ ។ សម័យនោះឯង ព្រះសង្ឃទាំងឡាយ បានសន្មតព្រះថេរ ៨ អង្គឲ្យទទួលភារធុរៈ ជាអ្នកពិភាក្សាសំរេចរឿងនោះ ហើយទើបនាំគ្នាទៅកាន់វត្ត

ភិក្ខុកាកមក្រុងវេសាលី ប្រជុំគ្នាជាសង្ឃសន្និបាតជំរះវត្ថុ ១០ ប្រការនោះ ហើយវិនិច្ឆ័យសំរេចសេចក្តីថាជាវត្ថុខុសបាកពុទ្ធបញ្ញត្តិ នាំឲ្យកើតអាបត្តិ (ទោស) ដល់ភិក្ខុអ្នកប្រព្រឹត្តកន្លង ។ ក្នុងសង្គីតិការៈនេះ ព្រះរេវតត្ថេរជាអ្នកបុច្ឆា ព្រះសព្វកាមិជាអ្នកវិសជ្ជនា ព្រមដោយព្រះសង្ឃជាអរហន្តចតុប្បដិសម្ភិទាញាណចំនួន ៧០០ អង្គ តាមរបៀបដែលព្រះអរហន្ត ៥០០ អង្គបានធ្វើមកហើយ មានព្រះបាទកាលាសោករាជជាពុទ្ធសាសនូបត្ថម្ភក៍ ធ្វើ ៨ ខែទើបសំរេច ។

## តតិយសង្គាយនា

ព្រះមហាថេរទាំងឡាយ បានលើកទុតិយសង្គាយនារួចហើយរំពឹងមើលទៅក្នុងអនាគតឃើញថា ដំណាតទៅខាងមុខ រាប់ព្រះពុទ្ធសាសនកាលបាន ២១៨ ឆ្នាំ ព្រះបាទធម្មាសោករាជទ្រង់ឧប្បត្តិឡើងក្នុងក្រុងបាតលីបុត្ត ហើយបានសោយរាជសម្បត្តិក្នុងសកលជម្ពូទ្វីប ទ្រង់មានព្រះទ័យជ្រះថ្លាក្នុងព្រះពុទ្ធសាសនា ហើយទ្រង់ញុំាងលាភសក្ការៈធំឲ្យប្រព្រឹត្តទៅ ម្យ៉ាងហើយពួកនិគ្រន្ថតិរ្ថិយ ដែលមានសេចក្តីក្រីក្រលំបាកប្រាថ្នាលាភសក្ការៈ ទឹងលបចូលបួសបួមបន្ទំក្នុងពុទ្ធសាសនមណ្ឌល ហើយយកលទ្ធិរបស់ខ្លួនមកសំដែងអាងថាជាពុទ្ធសាសនា, កាលបើយ៉ាងនេះព្រះពុទ្ធសាសនា ឈ្មោះថាមានមន្ទិលធំកើតឡើង ។ ...

គ្រានោះ ព្រះថេរទាំងឡាយរំពឹងឃើញថា តិស្សមហាព្រហ្ម គាប់ដំរេមនុស្សនោះបាន ទើបលោកហោះឡើងទៅកាន់ទេវលោកភាពនាតិស្សមហាព្រហ្មឲ្យទទួលភារៈ រួចហើយវិលត្រឡប់មកដាក់ធុរៈឲ្យព្រះសិគ្គវៈនឹងព្រះចន្ទវជ្ជី ដែលមិនបានចូលកាន់សង្ឃសន្និបាតក្នុងទុតិយ-សង្គាយនាឲ្យទទួលភារៈសំរេចឧបសម្បទាកិច្ច នឹង បង្រៀនព្រះបរិយត្តិ-ធម៌ដល់តិស្សមហាព្រហ្ម ដែលនឹងច្យុតមកកើតក្នុងត្រកូលនាងមោគ្គលី-ព្រាហ្មណីក្នុងកាលអនាគត ។

លុះដល់សម័យដែលតិស្សមហាព្រហ្មច្យុតមកកើតក្នុងត្រកូលនាងមោគ្គលីព្រាហ្មណីហើយ ព្រះសិគ្គវត្ថេរជាអ្នកទទួលបំបួស ព្រះចន្ទវជ្ជីជាអ្នកទទួលបង្រៀន ដរាបដល់ព្រះមោគ្គលីបុត្តតិស្សត្ថេរបានជាសង្ឃបាមោក្ខជាប្រធានរបស់សង្ឃក្នុងជំនាន់នោះ ។ ដល់មករជ្ជសម័យនៃព្រះបាទសិរីធម្មាសោករាជ កំមានមនុស្សកើតឡើងក្នុងពុទ្ធសាសនមណ្ឌល ដូចសេចក្តីយល់របស់ព្រះសង្គីតិកាចារ្យ ដែលបានពិចារណាឃើញគ្រប់ប្រការ, ព្រះសង្ឃបែកគ្នាខានធ្វើឧបោសថកម្មអស់ ៧ វស្សា ព្រះបរម-ក្សត្រាធិរាជប្រារព្ធនឹងជំរះមន្ទិលព្រះពុទ្ធសាសនា ទើបឲ្យយោធាមាត្យអង្កេតចាប់ពួកនិគ្រន្ថ ផ្សឹកអស់ហើយ ទុកតែព្រះសង្ឃដែលបរិសុទ្ធ ។ ទើបព្រះមោគ្គលីបុត្តតិស្សត្ថេរជ្រើសរើសតែព្រះអរហន្ត ដែលបានបដិ-សម្ភិទាញាណបែកធ្លាយក្នុងត្រៃបិដក បានចំនួន ១.០០០ អង្គ

នាំគ្នាធ្វើសង្គាយនាលើកព្រះពុទ្ធសាសនា ជាគ្រាទី ៣ ក្នុងអសោការាម ក្រុងបាតលីបុត្រមហានគរ តាមដំណើរដែលព្រះសង្គីតិកាចារ្យបុរាណបានធ្វើមកហើយ មានព្រះបាទសិរីធម្មាសោកជាសាសនូបត្ថម្ភក៍ អស់កាល ៩ ខែទើបសំរេច ។

## ចតុត្ថសង្គាយនា

ព្រះមោគ្គលីបុត្តតិស្សត្ថេរបានធ្វើតតិយសង្គាយនារួចហើយ រំពឹងមើលទៅក្នុងអនាគតឃើញថា ព្រះពុទ្ធសាសនា នឹងទៅប្រតិស្ឋានក្នុងបច្ចន្តប្រទេសទើបចាត់ព្រះអរហន្តទីណា ស្រេចឲ្យនាំព្រះពុទ្ធសាសនាទៅប្រតិស្ឋានទុកនៅប្រទេសផ្សេងៗ ។ ចំណែកព្រះមហិន្ទត្ថេរបានទទួលថេរបញ្ជាឲ្យទៅប្រកាសព្រះពុទ្ធសាសនានៅនាលង្កាទ្វីប ញុំាងព្រះបាទទេវានម្បិយតិស្សនិងអ្នកលង្កាឲ្យមានសេចក្ដីជ្រះថ្លា ។

គ្រានោះ ព្រះនាងអនុឡាដែលជាជាយារបស់ព្រះមហានាគឧបរាជ ជាព្រះរាជអនុជា មានប្រាថ្នាចង់បព្វជ្ជាជាភិក្ខុនី ។ ព្រះបាទក្រុងលង្កាទ្រង់បញ្ជូនរាជទូតទៅក្រុងបាតលីបុត្ត ជម្ពូទ្វីប ដើម្បីក្រាបទូលព្រះបាទធម្មា-សោករាជ សូមអារាធនាព្រះសង្ឃមិត្តាថេរីព្រះរាជធីតាមកសំរេចកិច្ចឧបសម្បទា ដល់ស្ត្រីជាតិសីហឡ: និង សូមអញ្ជើញមែកព្រះមហា-ពោធិព្រឹក្សមកផង ព្រះអង្គក៏ទ្រង់ព្រះរាជានុញ្ញាតតាម ។

កាលព្រះពុទ្ធសាសនារុងរឿងឡើងហើយ ព្រះចៅទេវានម្បិយតិស្ស ត្រាស់សួរព្រះមហិន្ទត្ថេរថា ព្រះពុទ្ធសាសនាបានឈ្មោះថាប្រតិស្ឋានស៊ប់ក្នុងទីនោះហើយឬនៅ? ព្រះថេរថ្វាយព្រះពរថា ព្រះពុទ្ធសាសនាដែលទឹងបានយាងចុះស៊ប់សួន លុះតែបានលើកតម្កើងព្រះធម្មវិន័យ ។ ស្តេចក៏ប្រារព្ធដើម្បីនឹងធ្វើសង្គាយនា ទើបទ្រង់អារាធនាព្រះមហិន្ទត្ថេរជាអ្នកប្រធាន ព្រះអរិដ្ឋមហាថេរជាអ្នកវិសជ្ជនា ។ ព្រះសង្ឃស្រុកលង្កាបានសូត្ររៀនចេះចាំព្រះពុទ្ធវចនៈ បែកធ្លុះធ្លាយឥតមានសល់ចំពាក់ទាក់ទើសអាចជាគណបាមោក្ខ ប្រៀនប្រដៅកុលបុត្រក្នុងទីនោះបាន ល្មមសន្និដ្ឋានថា ព្រះពុទ្ធសាសនាមានឫសចុះស៊ប់ក្នុងទីនោះមែន ។

សង្គាយនាគ្រានោះ បានធ្វើនៅក្នុងថូបារាមក្នុងអនុរាធបុរី ដោយគណសង្ឃ ៦៨ ០០០ អង្គ មានព្រះចៅទេវានម្បិយតិស្សជាសាសនូបត្ថម្ភក៍ អស់កាល ១០ ខែ ទើបសំរេច ក្នុងរវាងព្រះពុទ្ធសករាជ ២៣៦ វស្សា ។

## បញ្ចមសង្គាយនា

ព្រះបាទទេវានម្បិយតិស្ស ក្សត្រក្រុងលង្កាទ្វីប ទ្រង់មានបុញ្ញានុភាពប្រកបដោយបញ្ញាច្រើនបានបំពេញព្រះរាជកុសលផ្សេងៗ ជាអនេក ហើយស្តេចទិវង្គតទៅ ។ បន្ទាប់អំពីនោះមក ព្រះបាទឧត្តិយៈ, ព្រះបាទមហាសិវៈ និង ព្រះបាទសុរតិស្ស បានសោយរាជ្យជាលំដាប់គ្នាហើយ ទំនុកបម្រុងព្រះពុទ្ធសាសនាតរៀងមក ។

ចំណេរចិរកាលមកខាងក្រោយ វង្សក្សត្រលង្កាទ្វីបចេះតែទទួលគ្រោះថ្នាក់អំពីបច្ចាមិត្តរឿយៗ រហូតដល់ផ្លាស់ពូជវង្ស ម្ល៉ោះហើយព្រះពុទ្ធសាសនាចេះតែលិចអណ្តែត ៗ ទៅតាមវង្សក្សត្រដែលជ្រះថ្លា និងមិនជ្រះថ្លា ។

ដល់មកសម័យព្រះបាទវដ្តគាមិនីអភ័យ បានកំចាត់បច្ចាមិត្តអស់ ហើយទ្រង់បានសោយរាជ្យសម្បូណ៌ជាក្សត្រឯករាជ្យ ទ្រង់បានសាងវត្តអភយគិរីប្រគេនព្រះតិស្សត្ថេរ ព្រមទាំងទំនុកបម្រុងដោយចតុប្បច្ច័យបរិបូណ៌ ជាហេតុនាំឲ្យព្រះសង្ឃមហាវិហារកើតសេចក្តីច្រណែនលើកទោសព្រះតិស្សត្ថេរថា ច្របូកច្របល់ដោយគ្រហស្ថ ។ ខណៈនោះព្រះសង្ឃបែកគ្នាជា ២ ពួក គឺពួកខាងមហាវិហារ និងពួកអភយគិរីវិហារ ។

ក្នុងសម័យនោះ ពួកព្រះសង្ឃដែលមានប្រាជ្ញា ឃើញហេតុដែលនាំឲ្យសាបសូន្យព្រះពុទ្ធសាសនា ទើបនាំគ្នាលើកសង្គាយនាជាគ្រាទី ៤ គឺ ចារឹកព្រះត្រៃបិដកជាតួអក្សរដាក់ក្នុងស្លឹករឹតជាលើកដំបូងដែលប្រើអក្សរជាគ្រឿងកត់ត្រាព្រះពុទ្ធវចនៈ ។

សង្គាយនាលើកនេះ ធ្វើក្នុងមហាវិហារ នាលង្កាទ្វីប មានការកសង្ឃរាប់ពាន់អង្គ មានព្រះពុទ្ធទត្តត្ថេរជាប្រធានជាអ្នកបុច្ឆា ព្រះតិស្សត្ថេរជាអ្នកវិសជ្ជនា មានព្រះបាទវដ្តគាមិនីអភ័យជាពុទ្ធសាសនូបត្ថម្ភ អស់កាល ១ ឆ្នាំទើបសំរេច ។

(មានត)

# លោក ម៉ុញ ឆាត្រី តំណាងរាស្ត្រ រៀបរៀង

(តមក)

---

## ២ – ព្រហ្មញ្ញសាសនា

ព្រហ្មញ្ញសាសនា ជាសាសនាកើតក្ដកាលបរមបុរាណយូរអង្វែង លើសលែងសាសនាទាំងអស់ក្នុងលោក ចាប់កំណើតឡើងក្នុងមជ្ឈិម-ប្រទេស (ឥណ្ឌា) ឯណោះ ទើបផ្សាយកាយមកដល់ប្រទេសយើងជាខាងក្រោយ តែផ្សាយមកដល់មុនពុទ្ធសាសនា គឺសាសនាព្រាហ្មណ៍ទី ១ ពុទ្ធសាសនាទី ២ ។

សាសនានេះដែលបាននាមដូច្នេះសំគាល់សេចក្តីថា “សាសនារបស់ព្រះព្រហ្ម” ឬ “សាសនាតមកអំពីព្រះព្រហ្ម”, ពួកព្រាហ្មណ៍ដែលប្រកាន់ខ្លួនថាជាបុត្រព្រះព្រហ្ម កាន់តាមប្រតិបត្តិសាសនានេះ ទើបគេហៅថា សាសនាព្រាហ្មណ៍ ។

ពួកអ្នកកាន់សាសនាព្រាហ្មណ៍ តែងគោរពកប់កានបូជាពួកទេពតាដែលមានបណ្តាស័ក្តិច្រើនអង្គ គឺ ព្រះព្រហ្ម, ព្រះសិវៈ (ឥសូរ), ព្រះវិស្ណុ (នារាយណ៍), ព្រះឥន្ទ, ព្រះអាទិត្យ, ព្រះចន្ទ, ព្រះអគ្និ,

ព្រះវរុណ, ព្រះវាយុ (ពាយុ), ព្រះកុវេរ, ព្រះយម, ព្រះស្កន្ទ, ព្រះកាម ...(១) ។

ព្រះជាម្ចាស់ឬទេវតា ដែលពួកព្រាហ្មណ៍តែងគោរពរាប់អានបូជា នោះ មានច្រើនដូច្នេះក៏ពិតមែន តែដែលធំជាងគេនោះមាន ៣ គឺ: ព្រះព្រហ្ម, ព្រះសិវៈ និង ព្រះវិស្ណុ ។

## ព្រះព្រហ្ម

ព្រះព្រហ្ម សំដៅយកមហាព្រហ្ម មានជាយាឈ្មោះនាង សរស្វតី មានឱរសធីតា ៣ អង្គគឺ ព្រះទក្ស ១ ព្រះកឝ្យប ១ នាងសន្ធ្យា ១ ។

លក្ខណៈរបស់ព្រះព្រហ្ម គឺមានព្រះកាយសម្បុរក្រហម, ទ្រង់ព្រះពស្ត្រស, មានព្រះភក្ត្រ ៤, ព្រះហស្តកាន់ផ្កាឈូក, គង់លើហង្សជាពាហនៈ, ទ្រង់មានញាណពិសេស អាចជ្រាបហេតុគ្រប់កាលទាំងបី,

---

១ — ពួកទេវតាទាំងអស់នេះ សុទ្ធតែទ្រទ្រង់នូវគុណសម្បត្តិនិងមានមុខក្រសួងផ្សេងៗគ្នា គឺ ព្រះព្រហ្មជាអ្នកបង្កើតលោក, ព្រះសិវៈ ជាអ្នកបង្កើតលោកផងបំផ្លាញលោកផង, ព្រះវិស្ណុ ជាអ្នករក្សាលោក, ព្រះឥន្ទ្រជាម្ចាស់នៃខ្យល់ព្យុះ, ព្រះអាទិត្យជាម្ចាស់ពន្លឺក្តៅ, ព្រះចន្ទ្រ ជាម្ចាស់ពន្លឺត្រជាក់, ព្រះអគ្និជាមេភ្លើង, ព្រះវរុណជាមេភ្លៀង, ព្រះវាយុជាមេខ្យល់, ព្រះកុវេរជាម្ចាស់សម្បត្តិ, ព្រះយមជាស្តេចសេចក្តីស្លាប់, ព្រះស្កន្ទជាស្តេចសឹក, ព្រះកាមជាស្តេចសេចក្តីស្នេហា ។ ពួកទេវតាទាំងនេះលើកលែងតែព្រះវិស្ណុ, ព្រះអគ្និ, ព្រះវាយុ និងព្រះកាម ៤ អង្គនេះចេញ ក្រៅពីនេះហៅថា គណទេព (ទេពធំៗ) ព្រោះតែងចូលកាន់ទេវសន្និបាតជាប្រក្រតី ដើម្បីពិភាក្សាគ្នាអំពីហេតុភេទផ្សេងៗ ។ ពួកទេវតាដែលពួកព្រាហ្មណ៍តែងនិយមរាប់អានមិនអស់ហើយត្រឹមប៉ុណ្ណោះទេ នៅមានច្រើនតទៅទៀត ។

មានអានុភាពស័ក្តិសិទ្ធិ អាចបំពេញចិត្តនៃអ្នកប្រព្រឹត្តតាមឲ្យសំរេចប្រយោជន៍តាមត្រូវការ ។

ព្រះព្រហ្មជាបិតារបស់លោក (ជាជនករបស់លោក) ព្រោះគម្ពីរព្រហ្មបុរាណ៍សំដែងថា "មុនដែលនឹងកើតលោក ព្រះព្រហ្មផប់ឲ្យកើតពងមួយសិន ហៅថា "ពងព្រះព្រហ្ម" រួចហើយទ្រង់បែកភាគឲ្យកើតជាមនុស្ស ២ នាក់គឺ ប្រុស ១ ស្រី ១, ប្រុសហៅថាបុម, ស្រីហៅថាវិរជ្ជា, គូស្វាមីភរិយាទាំងនេះបានរួមរសប្រវេណីជាមួយគ្នា កើតជាពូជជារពាសពេញសកលលោក" ។ ហេតុនោះបានជាពួកព្រាហ្មណ៍ប្រកាន់ពួកខ្លួនថាជាវណ្ណខ្ពស់បំផុត ព្រោះជាវណ្ណរបស់ព្រះព្រហ្ម ។

## ព្រះសិវៈ

ព្រះសិវៈ ប្រែថា "ករុណា, គ្រៀមចាកទុក្ខភ័យ" កើតឡើងអំពីតំណក់លោហិតដែលស្រក់ចុះចាកចិញ្ចើមរបស់ព្រះព្រហ្ម, មានព្រះជាយានាមឧមាៈភាគវតី, មានបុត្រ ២ អង្គគឺ ព្រះវិឃនេស នឹងព្រះកត្រិគេយ (ស្កន្ទ-កុមារ), មានគោឧសភឈ្មោះ នន្ទិយ ជាពាហនៈ ។ លក្ខណៈរបស់ព្រះអង្គគឺមានព្រះកាយសម្បុរស, ព្រះសុរង្គសម្បុរខៀវ, ទ្រង់ស្បែកខ្លា ប៉ុងរ៍ជាព្រះវស្ត្រ, មានព្រះមោលីសម្បុរលឿងក្បួចផ្តុំគ្នាលើព្រះសិរ, មានព្រះនេត្រ៣គឺពីរដូចមនុស្សធម្មតា មួយទៀតចំកណ្តាលព្រះនលាដៈ (ថ្ងាស),

មានពុកចង្កាវែងបែបព្រាហ្មណ៍, មានទាគជាសន្ទារ (ជាគ្រឿងកប់ឆ្នាំ), មានពិណព្រះចន្ទ្រចាំងរស្មីព្រោតៗ (ជាគ្រឿងសំគាល់កប់វែង), មានឆ្អឹងលលាដ៍ក្បាល.. (ជាគ្រឿងសំគាល់កល្បយុគ), ទ្រង់អាវុធឈ្មោះចក្រ-ករ៍ នឹងគទា (ដំបង) ព្រះខាន់ឫសារ ត្រីសូល៍, មានស្គរឈ្មោះឌុមរូ, ទ្រង់ស្ទាត់ជំនាញខាងសិល្បសាស្ត្រ នឹង នាដសាស្ត្រ, ជាមហាយោគី ទ្រទ្រង់នូវអានុភាពនៃព្រះគុណ, ឋិតនៅក្នុងវិមាននៅលើកំពូលភ្នំកៃលាស ។ ព្រះសិវៈជាបិតារបស់លោក ជាអ្នកកសាងលោក, ព្រោះមានសេចក្តីក្នុងគម្ពីរព្រាហ្មណ៍ ឈ្មោះសិវបុរាណម នឹងឈ្មោះកថាសរិតសាគរ សំដែងថា: “ទ្រង់វះសាច់ភ្លៅឲ្យឈាមមួយដំណក់ស្រក់ចុះទៅក្នុងទឹក កើតឡើងជាពងមួយ ហើយបែកទៅជាពីរចំហៀង, មួយចំហៀងកើតជាសួគ៌លោក មួយចំហៀងទៀតកើតជាមនុស្សលោក ទើបកើតជាបុម (បុរស), បុមនោះបង្កើតជាប្រជាបតីៗបង្កើតមនុស្សតៗមក” ។

អាស្រ័យដំនៀលថា ព្រះសិវៈជាបិតាលោក ទើបព្រាហ្មណ៍និកាយប្រឌិតសាងអនុស្សាវរីយទុកជាទីរលឹក គឺធ្វើរូបសិវលិង្គ (លិង្គព្រះឥស្វរ) នឹងរូបឧមាយោនី (យោនីនាងឧមា) ទុកសម្រាប់ធ្វើពិធីសិវរាត្រី លាងបាប លាងចង្រៃឧបទ្រពចាំងតួន ។

# ព្រះវិស្ណុ

ព្រះវិស្ណុ ឬ ព្រះនារាយណ៍ មានលក្ខណៈរូបដោយសម្បុរខ្មៅ, ព្រះហស្តប្រក្រតីតែពីរ តែអាចបែងចេញទៅជា ៤ ឬ ៨ ក៏បាន, ព្រះឧរមានលាយល័ក្ខណ៍ផ្សេងៗ ហៅថាស្រីវត្ស, ទ្រង់អាភរណៈចីពរពណ៌លឿង, ទ្រង់ស័ង្ខឈ្មោះបញ្ចជន្យជាអាវុធ, ចក្រឈ្មោះសុទស្សនៈ, គទាឈ្មោះកៅមោទកី, ធ្នូឈ្មោះសារង្គ, ព្រះខ័នខាន់ឈ្មោះនន្ទក, កាន់ផ្កាឈូកជាគ្រឿងសំគាល់, មានគ្រុឌបក្សីជាពាហនៈ, ព្រះជាយានាមលក្ស្មី, មានឧរសៈឈ្មោះកាមទេព, ទីដែលស្ថិតនៅឈ្មោះវៃកុណ្ឋ ។

ព្រះទាំង ៣ អង្គនេះ មានគុណសម្បត្តិផ្សេងៗគ្នា គឺ ព្រះព្រហ្មជាអ្នកសាងលោក, ព្រះឥសូរជាអ្នកសាងលោកផង បំផ្លាញលោកផង, ព្រះវិស្ណុជាអ្នកជួយស្រោចស្រង់លោក ទើបមាននាមថា ហរិ "ករុណា" នារាយណ៍ "ជាដែនកើតនៃនរជន" ។

# គម្ពីរត្រៃវេទ

ព្រាហ្មណសាសនិកជន រមែងគោរពបូជាទេវតាដូចបានពោលមក ហើយ ទីង ប្រតិបត្តិតាមគម្ពីរត្រៃវេទនិងវេទាង្គជាគម្ពីរធំ ។

ឯគម្ពីរត្រៃវេទនោះមាន ៣ គឺ :

១ – គម្ពីរសាមវេទ សំដែងអំពីពិធីការក្នុងពលីកម្ម បួងសួងសូមឲ្យព្រះឥន្ទ្រនិងព្រះពរុណាជួយអភិបាលមនុស្សលោក ឲ្យមានភ្លៀងធ្លាក់ត្រូវតាមរដូវកាល ។

២ – គម្ពីរអេសូវេទ ឬ ឥរុវេទ សំដែងអំពីពិធីតុស្តិ៍, សូមឲ្យព្រះវិស្វកម្ម ព្រះមារុត ព្រះព្រហ្ម ប្រទានពរឲ្យសំរេចកិច្ចខាងការហោត្តកម្មពាណិជ្ជកម្ម និងលាភសក្ការៈផ្សេងៗ តាមត្រូវការ ។

៣ – គម្ពីរយជុវេទ សំដែងអំពីពិធីយុទ្ធពលីកម្មដល់ព្រះឥស្សរ, ព្រះនារាយណ៍, ព្រះអាទិត្យ, ព្រះអគ្គី, សូមឲ្យមានរិទ្ធិតេជះ ជោគជ័យ ។

បណ្ដាវេទទាំង ៣ នេះ មួយៗចែកជាពីរផ្នែកគឺ វេទឬព្រហ្ម ១ ផ្នែក, មន្ត ១ ផ្នែក ។ វេទ និយាយអំពីរបៀបធ្វើពលីកម្ម, មន្ត បានដល់ពាក្យស្លោក ( គាថា ) សម្រាប់សូត្របួងសួងបន់ស្រន់ និង សរសើរព្រះជាម្ចាស់ ។

ព្រាហ្មណ៍ដែលកំពុងសិក្សាត្រៃវេទនេះ ហៅថា ព្រហ្មចារី "អ្នកប្រព្រឹត្តព្រហ្មគីវេទ", អ្នករៀនចេះចប់ហើយហៅថា វេទគូ "អ្នកដល់នូវទីបំផុតនៃវេទ" ឬ បារគូ "អ្នកដល់នូវត្រើយនៃវេទ" ។ ហេតុនោះ ព្រាហ្មណ៍ទើបមាន ២ ពួក គឺ ព្រាហ្មណ៍ដោយជាតិ ១ ព្រាហ្មណ៍ដោយគុណធម៌ ១ ។

## សេចក្ដីបដិបត្តិក្នុងលទ្ធិព្រហ្មញ្ញ

អ្នកកាន់លទ្ធិនេះយល់ថា លោកធាតុទាំងវត្ថុធាតុ ធម្មជាតិទាំងអស់ក្នុងពិភពលោកនេះ សុទ្ធតែព្រះទ្រង់សាងឡើង ហើយសុទ្ធតែមានទេពតាប្រចាំ សុទ្ធតែមានទេពតាជាម្ចាស់; ហេតុនេះ ត្រូវតែប្រតិបត្តិខ្លួនឲ្យត្រូវព្រះទ័យព្រះជាម្ចាស់ទាំងពួកទេពតា ទើបមានសេចក្ដីសុខចំរើន ។

ឯកិច្ចដែលត្រូវប្រតិបត្តិនោះ មាន៣យ៉ាង គឺ:

១ – កិច្ចបំពេញតប:

២ – ពិធីបូជាព្រះអគ្គី ឬ បូជាយញ្ញ

៣ – ពិធីសិវរាត្រី ( លាងបាប ) ។

**កិច្ចបំពេញតប:** គឺទរមានរាងកាយឲ្យលំបាកដោយកិច្ចវត្តផ្សេងៗ មានប្រព្រឹត្តវត្តឈរជាដើម ឲ្យតាល់តែលំបាកទៀបស្លាប់ឬស្លាប់ទៅក៏មាន ដើម្បីឲ្យក្ដៅរំដួលដល់ព្រះជាម្ចាស់ ហើយទ្រង់ប្រសិទ្ធិប្រទានពរឲ្យតាមប្រាថ្នា ។

**ពិធីបូជាព្រះអគ្គី** នោះចែកចេញជា ៤ គឺ បង្រៀនវេទដល់សិស្សគណ ហៅថា បូជាវេទ ១, សែនព្រេនដោយគ្រឿងសំណែនមានទឹកជាដើម ហៅថា បូជា . . . ១, ដុតរបស់ក្នុងភ្នក់ភ្លើងថ្វាយទេពតា ហៅថា បូជា . . . . ១, ឲ្យអាហារជាទាន ហៅថា បូជាសត្វ ១ ។

**ពិធីសិវរាត្រី** សម្រាប់ប្រទេសតេណ្ហា). គេធ្វើក្នុងទន្លេគង្គា ដោយគេយល់ថា ជាមេទឹកស័ក្តិសិទ្ធិដែលហូរចុះមកពីឋានសួគ៌ សម្រាប លាងជំរះបាបរបស់សត្វ ។

ពិធីនេះ ពួកព្រាហ្មណ៍ស្រុកពារាណសី វេលាយប់នាំគ្នាទៅវត្ត ព្រាហ្មណ៍ ដែលជាទេវឋាន ធ្វើកិច្ចសូត្រមន្ត បំរើទេវតា ឧមស្វការ ទេវរូបទឹងសិវលិង្គ តាមប្រវេណីរហូតអស់រាត្រី, ទៀបភ្លឺ ទើបនាំគ្នាយក ក្អមស្ពាន់មួយៗម្នាក់ទៅកាន់ស្ទឹងគង្គា អង្គុយដងយកមកសូត្រសេក ខ្ទុរ មាត់លុបលាងខ្លួនប្រាណ ហើយចុះងូតមុជឲ្យលិចក្បាលអស់វារៈ ៣ ដង ហើយមុជទេះយកដីមកដុះខ្លួនប្រាណ ទាំង ធ្វើបរិកម្មថា "គង្គា! គង្គា!" កិច្ចប៉ុណ្ណេះ ឈ្មោះថាបានជំរះលាងបាបអស់អំពីខ្លួនស្អាត រួចហើយទើប ដងទឹកយកមកកាន់ទេវឋានវិញ ដល់ហើយយកទឹកនោះទៅស្រោចស្រប់ សិវលិង្គ ទើបត្រង់ទឹកដែលហូរចុះតាមទ្រនៀបលិង្គមារយោនី យកមក ស្រោចក្បាល ស្រលាបខ្លួនប្រាណ ផឹកតាមសេចក្តីត្រូវការ ឈ្មោះថា បានសិរីសួស្តីជ្រះអស់ចង្រៃឧបទ្រពទាំងពួង ។

ឯកំពង់សម្រាប់ចុះងូតនោះ តាមដែលគេសម្មតិទុកមាន ៣ អន្លើគឺ កំពង់ព្រះព្រហ្ម ១ កំពង់ព្រះវិស្ណុ ១ កំពង់ព្រះឥសូរ ១ ។ កំពង់ទាំង ៣ នេះ មានគុណផ្សេងៗគ្នា ស្រេចហើយតែអ្នកត្រូវការចង់ចុះងូតកំពង់

ណាក៏បាន ។ ត្រង់ជ្រោយស្រុកអល្លហបាទ មានកំពង់មួយស័ក្តិសិទ្ធិផងដែរ ហៅថា "ប្រយាគ" មានប្រជុំជននិយមចុះងូតរាប់ទាំងសែន ។

សម្រាប់ស្រុកភូមិដែលនៅឆ្ងាយអំពីទន្លេគង្គា, បើអ្នកណាបាននៅងូតម្តងៗ តែងដងយកទឹកនោះមកផ្ញើញាតិមិត្ត ឲ្យលុបលាងមុខមាត់ស្រលាបខ្លួនប្រាណហើយបរិកម្មថា "គង្គា! គង្គា!", សូម្បីនៅចម្ងាយ ៣០ យោជន៍ ក៏គង់រួចចាកបាបដែលខ្លួនបានធ្វើមក ៣ ជាតិហើយ ។

ហេតុនេះ ទើបបានជាពួកឥណ្ឌា, ដែលមានសទ្ធាជ្រះថ្លាខ្លាំង វេលាទៀបស្លាប់ឲ្យបាននៅស្លាប់ក្បែរទន្លេគង្គា ស្លាប់ហើយឲ្យគេដុតយកធាតុទៅត្រវែងបាចសាចចោលក្នុងទន្លេនោះ ឈ្មោះថាបានជ្រះបាបឥតសេសសល់ ។

សម្រាប់ប្រទេសឆ្ងាយៗ ក្រៅពីប្រទេសឥណ្ឌា, ពិធីសិវរាត្រីនេះគេយកសិវលិង្គទៅដំកល់ទុកក្នុងទីណាមួយ ហើយដាំសសរ ៤ ជុំវិញសិវលិង្គ រួចយកខ្សែចងខ្វែងសសរទាំងនោះ ទើបយកក្អមឬឆ្នាំងចោះធ្លុះ ហើយយកមកព្យួរនឹងខ្សែនោះឬចងនឹងមែកឈើក៏បាន ហើយដាក់ទឹកក្នុងឆ្នាំងនោះ ឲ្យស្រក់ចុះមកចំលើលិង្គនោះ ដើម្បីឲ្យហូរទៅតាមបល្ល័ង្កឧមាយោនី ដរាបដល់អស់រាត្រីកាល, ដល់វេលាទៀបភ្លឺគេនាំគ្នាដណ្តាំបាយ លាយដោយទឹកដោះ ទឹកឃ្មុំ ស្ករនឹងគ្រឿងទេសផ្សេងៗ ដែលចាត់ថាជាបណីតាហារ នាំគ្នាបរិភោគ ហើយទៅងូតទឹកទន្លេឬព្រែកជំនួស

ទន្លេគង្គា រួចហើយទើបយកទឹកសិរីសួស្តី ស្រោចស្រប់ខ្លួនព្រាហ្មណ៍ថែមទៀត កិច្ចប៉ុណ្ណោះឈ្មោះថាស្រេចកិច្ចសិវរាត្រី ។

ពិធីនេះ គេធ្វើក្នុង ១ ឆ្នាំតែម្តង ហើយបានធ្វើក្នុងវេលារាត្រីផង ទើបហៅថា ពិធីសិវរាត្រី ។

## ផលនៃការប្រតិបត្តិក្នុងលទ្ធិព្រាហ្មណ៍

និកាយព្រាហ្មណ៍គោរពរាប់អាន ព្រះព្រហ្ម ព្រះឥសូរ ព្រះនារាយណ៍ និង ប្រព្រឹត្តតាមពាក្យប្រដៅក្នុងគម្ពីរត្រៃវេទ ។ ផលប្រយោជន៍ក្នុងការប្រតិបត្តិមាន ២ យ៉ាងគឺ ១ – ប្រយោជន៍ក្នុងលោកនេះ, ២ – ប្រយោជន៍ក្នុងលោកខាងមុខ ។ ប្រយោជន៍ទី ១ សម្រាប់ពួកគ្រហស្ថ, ប្រយោជន៍ទី ២ សម្រាប់ពួកបព្វជិតដែលនឿយណាយក្នុងឃរាវាសកិច្ច ហើយចេញទៅបួសជាតាបស - ឫសី ស្ងប់ស្ងាត់ប្រព្រឹត្តតបៈផ្សេងៗក្នុងព្រៃភ្នំក្រំច្ច មានផ្លែឈើមើមឈើជាអាហារ ដើម្បីឲ្យបានលុះគុណវិសេសជាន់ខ្ពស់ ។

បព្វជិតដែលប្រព្រឹត្តតឹងរឹងដល់កំរិតដល់ថ្នាក់ ចាត់ថាជាអ្នកបានលុះគុណវិសេសនោះៗហើយ ចែកជា ៤ ពួកគឺ: ១ – រាជឫសី, ២ – មុនី, ៣ – មហាឫសី, ៤ – ព្រហ្មឫសី ។

សរុបយោបល់: ឫសីទាំង ៤ នេះ សឹងនៅប្រកបដោយកាមកិលេសនៅឡើយ ព្រោះមានរឿងដំណាលថា ឫសីខ្លះមានប្រពន្ធកូន, ខ្លះញុះញង់សម្លាប់គេជាដើម កុំថាឡើយតែពួកព្រហ្មឫសីទេដែលទំ

ប្រតិបត្តិផលថ្នាក់ត្រឹមឫស៊ីប៉ុណ្ណោះ សូម្បីព្រះព្រហ្ម ព្រះសិវៈ ព្រះវិស្ណុ ដែលគេប្រកាន់ថាជាព្រះមេលទ្ធិសាសនា ក៏សុទ្ធតែនៅមានប្រពន្ធកូន មានកំហឹង មានសេចក្ដីព្យាបាទបៀតបៀនអ្នកដទៃនៅឡើយ, បើតាមសេចក្ដីសង្កេតទៅឃើញថា ពួកទេពតានិងឫស៊ីទាំងនោះនៅមានរាគៈ ទោសៈ មោហៈ ដូចបុថុជ្ជនធម្មតា ។

---

## លទ្ធិគ្រូ ៦

ក្នុងសម័យពុទ្ធកាល ពាហិរសាសនាក្រៅអំពីសាសនាព្រាហ្មណ៍ នៅមានលទ្ធិដទៃៗទៀត ដែលជាលទ្ធិផ្ទុយទាស់នឹងព្រះពុទ្ធសាសនា គឺ លទ្ធិគ្រូ ៦ ។

ឯឈ្មោះគ្រូទាំង៦នោះ គឺបូរណកស្សប ១ មក្ខលិគោសាល ១ និគណ្ឋនាដបុត្ត ១ សញ្ជយវេលដ្ឋបុត្ត ១ បកុទ្ធកច្ចាយន ១ អជិតកេសកម្ពល ១ ។

## ប្រវត្តិរបស់គ្រូទាំង ៦ (សង្ខេប)

១ – **បូរណកស្សប** គ្រូនេះមានសេចក្ដីដំណាលថា: មានត្រកូលអ្នកមានម្នាក់ មានខ្ញុំប្រុស-ស្រីចំនួន៩៩នាក់, ក្នុងចំណោមខ្ញុំទាំងនេះ មានខ្ញុំម្នាក់មានកូនប្រុសមួយទើបនឹងកើតមក រួមទាំងខ្ញុំមុនផងត្រូវជា ១០០ ទើបគេកំណត់ឲ្យឈ្មោះទារកក្រោយនេះថា បូរណៈ ប្រែថា "បំពេញ" ព្រោះបង្គ្រប់ជា ១០០ នឹងខ្ញុំមុន ចាត់ថាជាខ្ញុំមង្គល ។

អាស្រ័យហេតុនេះ ទោះបីជាគេនោះ ធ្វើកិច្ចការអ្វីល្អក្តី អាក្រក់ក្តី ឬធ្វើក្តី មិនធ្វើក្តី ក៏ចៅហ្វាយនាយ មិនដែលស្តីបន្ទោសសោះឡើយ ។

ថ្ងៃមួយ ទំប្រុសនោះគិតឃើញថា "ការដែលនៅទទេៗ ដូច្នេះមិនមានប្រយោជន៍អ្វីឡើយ", ទើបគេចេញចាកទីនោះទៅ, លុះគេទៅដល់ប្រទះនឹងចោរៗ ដណ្តើមយកសំពត់សម្លៀកបំពាក់អស់រលីង រកអ្វីស្លៀកមិនបាន ក៏ចូលទៅកាន់ភូមិមួយទាំងខ្លួនអាក្រាតទទេ ។ ពួកមនុស្សអ្នកស្រុកឃើញដូច្នោះ ក៏យល់ឃើញថាជាសមណៈអរហន្ត អ្នកមានសេចក្តីប្រាថ្នាតិច រកបុគ្គលដទៃស្មើគ្មាន, ហើយនាំគ្នាបូជាដោយនំចំណីផ្សេងៗ ។ បុរសអាក្រាតនោះឯង អាស្រ័យរឿងនេះ ទើបកើតគំនិតថ្មីឡើងថា "លាភសក្ការៈទេយ្យវត្ថុទាំងនេះដែលកើតឡើងដល់អញ ព្រោះអាស្រ័យការអាក្រាតកាយ បើដូច្នោះមិនត្រូវស្លៀកសំពត់ទេ" ម្ល៉ោះហើយចាប់ផ្តើមតាំងអំពីកាលនោះមក ទោះបីមានសំពត់ក៏មិនស្លៀកដណ្តប់ឡើយ ហើយប្រកាន់យកការអាក្រាតកាយនោះថាជាកិច្ចបត្តិ ជាភេទរបស់អ្នកបួស, តមកទើបមានមនុស្សជាច្រើនរយចូលបួសក្នុងសំណាក់គ្រូនោះ ។

លទ្ធិរបស់គ្រូនេះ ជាអកិរិយវាទ (ប្រកាន់ថាមិនមានអំពើ) គឺប្រកាន់ថាបុគ្គលដែលធ្វើអំពើបាបផ្សេងៗ មានការសម្លាប់សត្វ លួចទ្រព្យអ្នកដទៃ ធ្វើបរទារកម្ម និយាយមុសាវាទជាដើម មិនឈ្មោះថា

ធ្វើអំពើបាបទេ មិនមានបាបទេ ឥតមានទោសឡើយ ។ ហេតុនោះគ្រូនេះឈ្មោះថា អកិរិយវាទី "អ្នកពោលប្រកាន់ថាមិនមានអំពើ" ។

២ – មក្ខលិគោសាល គ្រូនេះមានរឿងដំណាលថា គាត់កើតក្នុងរោងគោឆាគសះរបស់ជនម្នាក់ ។ លុះធំឡើង ទៅហ្វាយបានប្រើឲ្យកាន់ឆ្នាំងខ្លាញ់ដើរកណ្ដាលភក់ក្រៀង ប្រកបដោយដីអិលប៉ុចប៉ាច់ ហើយហាមប្រាម (តាមភាសាបាលី) ថា: មា ខលិ "ប្រយ័ត្នរអិល" ថាមិនទាន់ផុតមាត់រអិលដួលព្រះ, ដោយសារសេចក្ដីខ្លាចម្ចាស់ គាត់ក៏រត់ទៅបណ្ដោយ, ទៅហ្វាយក៏ដេញតាមចាប់ជាយសំពត់ជាប់ គាត់ប្រឹងបំរះរបូតទៅ សល់នៅតែកាយទទេហើយរត់បាត់ទៅ ។

ពួកមនុស្សដែលឆោតល្ងង់ខ្លៅ ឃើញដូច្នោះក៏សំគាល់ថាជាព្រះអរហន្ត មានសេចក្ដីប្រាថ្នាតិច, ហើយនាំគ្នាគោរពបូជា ។ បុរសនោះអាស្រ័យលាភសក្ការៈក៏ឡើងដោរ . សំគាល់ខ្លួនថាជាព្រះអរហន្តមែន ហើយប្រព្រឹត្តវត្តអាក្រាតកាយនោះតមក ។

ឯលទ្ធិរបស់គ្រូនេះ ជាអហេតុកទិដ្ឋិ (ប្រកាន់ថាមិនមានហេតុបច្ច័យ) គឺប្រកាន់ថា: នត្ថិ ហេតុ នត្ថិ បច្ចយោ សត្តានំ សង្កិលេសាយ មិនមានហេតុមិនមានបច្ច័យដើម្បីញុំាងសត្វឲ្យសៅហ្មង, អហេតូ អប្បច្ចយា សត្តា សង្កិលិស្សន្តិ សត្វទាំងឡាយមិនមានហេតុមិនមានបច្ច័យ នាំឲ្យសៅហ្មងទេ. នត្ថិ ហេតុ នត្ថិ បច្ចយោ

សត្តានំ វិសុទ្ធិយា មិនមានហេតុ មិនមានបច្ច័យ ញុំាងសត្វទាំង-ឡាយឲ្យបរិសុទ្ធ, អហេតូ អប្បច្ចយា សត្តា វិសុជ្ឈន្តិ សត្វទាំងឡាយមិនមានហេតុ មិនមានបច្ច័យនាំឲ្យបរិសុទ្ធ (សត្វដែលនឹងសៅហ្មងក៏សៅហ្មងឯង, នឹងបរិសុទ្ធក៏បរិសុទ្ធឯង) ។ ហេតុនោះគ្រូនេះទើបឈ្មោះថា ជាអហេតុកវាទី "អ្នកពោលប្រកាន់ថាមិនមានហេតុ" ។

៣– **និគណ្ឋនាដបុត្ត** (គ្រូនេះមានរឿងដំណាលថា: គាត់ជាកូនរបស់អ្នករបាំ (នាដបុត្ត) មានសេចក្តីប្រកាន់មានដើមថា: អម្ហាកំ គណ្ឋនត្ថិ លេសោ នត្ថិ យើងមិនមានកិលេសជាគ្រឿងចាក់ស្រេះរឹគ្រូតទេ, គិលេសគណ្ឋរហិតា យើងប្រាសចាកគ្រឿងចាក់ស្រេះរឹគ្រូតគឺកិលេសហើយ ។

ម្យ៉ាងទៀត លទ្ធិរបស់គ្រូនេះ ប្រកាន់យកការសង្រួមទាំង ៤ គឺ: សព្វវារិវារិតោ ឃាត់ហាមទឹកទាំងពួង ១ សព្វវារិយុត្តោ ប្រកបដោយទឹកទាំងពួង ១ សព្វវារិធុតោ កំចាត់បាបដោយទឹកទាំងពួង ១ សព្វវារិផុដោ ច្រោះព្រំដោយទឹកទាំងពួង១, បុគ្គលដែលប្រកបដោយការសង្រួមទាំង ៤ យ៉ាងនេះឈ្មោះថា ជាអ្នកដល់នូវទីបំផុត ជាអ្នកសង្រួម ជាអ្នករក្សាខ្លួនបានល្អ ។

គ្រូនេះជា និគណ្ឋវាទី អ្នកប្រកាន់ថាខ្លួនមិនមានកិលេស មិនមានគ្រឿងសៅហ្មង ។

៤– **សញ្ជ័យ** គ្រូនេះមានសេចក្ដីថា: គាត់ជាកូនអ្នកត្បាញផែន (វេលដ្ឋបុត្ត) ទើបគេហៅថា សញ្ជ័យវេលដ្ឋបុត្ត ។

ឯលទ្ធិរបស់គ្រូនេះ ប្រកាន់អមរាវិក្ខេបទិដ្ឋិ គឺសេចក្ដីយល់ប្រកបដោយកពាមិនស្លាប់, ឬសេចក្ដីយល់បម្រះដូចជាអន្ទង់, សេចក្ដីយល់ពាក់បណ្ដាយ, និយាយដោះខ្លួនឲ្យតែរួចមិនឲ្យគេចាប់ជាក់បាន ។ បើមានគេសួរថា លោកខាងមុខមានឬមិនមាន? ពួកសត្វជាឧបបាតិកមានឬមិនមាន? ផលវិបាកនៃកម្មល្អនិងកម្មអាក្រក់មានឬមិនមាន? ។ គាត់ឆ្លើយថា បើសេចក្ដីយល់របស់ខ្ញុំថាមាន ខ្ញុំឆ្លើយថាមាន, បើមិនមាន–ថាមិនមាន, បើមានខ្លះ មិនមានខ្លះ–ថាមានខ្លះមិនមានខ្លះ, បើមានក៏មិនមែនមិនមានក៏មិនមែន – ថាមានក៏មិនមែនមិនមានក៏មិនមែន, តែសេចក្ដីយល់របស់ខ្ញុំយ៉ាងនេះក៏មិនមែន យ៉ាងនោះក៏មិនមែន យ៉ាងដទៃក៏មិនមែន ថាមិនមែនក៏ទេ ថាមិនមែនទេក៏ទេដែរ ។ បើមានគេសួរថា សត្វស្លាប់ហើយកើតទៀត ឬមិនកើតទៀត? ។ គាត់ឆ្លើយថា បើសេចក្ដីយល់របស់ខ្ញុំថាកើតទៀត ខ្ញុំនឹងឆ្លើយថាកើតទៀត, បើមិនកើតទៀត - ថាមិនកើតទៀត, កើតទៀតខ្លះ មិនកើតទៀតខ្លះ - ថាកើតទៀតខ្លះមិនកើតទៀតខ្លះ, កើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែន - ថាកើតទៀតក៏មិនមែនមិនកើតទៀតក៏មិនមែន, តែសេចក្ដីយល់របស់ខ្ញុំយ៉ាងនេះក៏មិនមែន

យ៉ាងនោះក៏មិនមែន យ៉ាងដទៃក៏មិនមែន - ថាមិនមែនក៏ទេ ថាមិនមែនទេក៏មិនមែនដែរ ។

ទិដ្ឋិរបស់គ្រូនេះ ហៅថា អមរាវិក្ខេបទិដ្ឋិ "សេចក្ដីយល់ប្រែកបដោយរក់ថាមិនស្លាប់" ឬ "សេចក្ដីយល់បម្រះដូចជាអន្ទង់" ។

**៥ - បកុទ្ធកច្ចាយនៈ** គ្រូនេះមានរឿងដំណាលថា: គាត់ជាអ្នកប្រតិសេធមិនប្រើប្រាស់ទឹកត្រជាក់ ដោយយល់ឃើញថាមានសត្វកាស្រ័យនៅ ។ គ្រូនេះសូម្បីបន្ទោបង់នូវលាមកក្ដី បរិភោគភោជនក្ដី ប្រឡាក់ដោយវត្ថុមិនស្អាតណាមួយហើយ មិនព្រមប្រើប្រាស់ធ្វើកិច្ចនោះ ៗ ដោយទឹកទេ កាលបើបានទឹកក្ដៅ ឬ ទឹកបាយទើបធ្វើកិច្ចទាំងនោះ ។ កាលបើដើរឆ្លងស្ទឹង ឬ ឆ្លងទឹកដែលមាននៅក្នុងផ្លូវ តែងធ្វើផ្ទុកខ្សាច់អធិដ្ឋានសីលរួចហើយទើបដើរឆ្លងហួសទៅ ដោយយល់ឃើញថា បើមិនបានធ្វើយ៉ាងនេះនឹងដាច់សីល ។

ម្យ៉ាងទៀតគ្រូនេះយល់ថា កាយ៧យ៉ាងគឺ បឋវីកាយ (ពួកធាតុដី)១ អាបោកាយ (ពួកធាតុទឹក)១ តេជោកាយ (ពួកធាតុភ្លើង)១ វាយោកាយ (ពួកធាតុខ្យល់)១ សុខៈ (សេចក្ដីសុខ)១ ទុក្ខៈ (សេចក្ដីទុក្ខ)១ ជីវិតៈ (ជីវិត)១ គ្មាននរណាធ្វើកើតនិម្មិតបានសាងបានទេ ជាសភាវៈអាតាំងនៅមាំដូចជាកំពូលភ្នំ ឬ ដូចជាសសរគោល មិនចេះញាប់ញ័រប្រែប្រួល មិនចេះបៀតបៀនគ្នា មិនអាចធ្វើគ្នាឲ្យបានសុខ - ទុក្ខទេ (ហេតុនោះ)

បុគ្គលសម្លាប់ខ្លួនឯងក្តី ឲ្យគេសម្លាប់ក្តី ស្លាប់ខ្លួនឯងក្តី ប្រើគេឲ្យស្លាប់ក្តី ដឹងខ្លួនឯងក្តី ញុំាងអ្នកដទៃឲ្យដឹងច្បាស់ក្តី មិនមានទៅក្នុងកាយទាំងនោះឡើយ ទុកណាជាបុគ្គលនោះកាត់សីសៈដោយគ្រឿងសស្ត្រាដ៏មុត ក៏ឈ្មោះថាគ្មាននរណាសម្លាប់អ្នកណាទេ គ្រឿងសស្ត្រានោះគ្រាន់តែចូលទៅកាន់ចន្លោះកាយទាំង ៧ ប៉ុណ្ណោះឯង ។

គ្រូនេះជា អកិរិយវាទ "អ្នកប្រកាន់ថាមិនមានអំពើ" ។

៦ – **អជិតកេសកម្ពល** គ្រូនេះប្រើប្រាស់តែសំពត់កម្ពលធ្វើពីសក់មនុស្ស ប្រកាន់ឧច្ឆេទទិដ្ឋិ "សេចក្តីយល់ឃើញថាសូន្យ" គឺប្រកាន់ថា:

១ – នត្ថិ ទិន្នំ ទានដែលបុគ្គលឲ្យហើយមិនមានផល

២ – នត្ថិ យិដ្ឋំ ការបូជាធំមិនមានផល

៣ – នត្ថិ ហុតំ ការបូជាតូចមិនមានផល

៤ – នត្ថិ សុកតទុក្កដានំ កម្មានំ ផលវិបាកោ ផលវិបាកនៃកម្មដែលបុគ្គលធ្វើល្អនិងធ្វើអាក្រក់មិនមាន

៥ – នត្ថិ អយំ លោកោ លោកនេះមិនមាន

៦ – នត្ថិ បរោ លោកោ លោកខាងមុខមិនមាន

៧ – នត្ថិ មាតា សេចក្តីប្រតិបត្តិក្នុងមាតាមិនមានផល

៨ – នត្ថិ បិតា សេចក្តីប្រតិបត្តិក្នុងបិតាមិនមានផល

៩ – នត្ថិ សត្តា ឱបបាតិកា សត្វជាឧបបាតិកមិនមាន

១០ – នត្ថិ លោកេ សមណព្រាហ្មណា សម្មគ្គតា សម្មាបដិបន្នា ពួកសមណនិងព្រាហ្មណ៍ ដែលមានសេចក្ដីព្រមព្រៀងគ្នា ប្រតិបត្តិដោយប្រពៃ ក្នុងលោក មិនមាន ។

មួយទៀត ប្រកាន់ថាបុរសដែលប្រកបដោយមហាភូតរូប ៤ បែកធ្លាយរាងកាយទៅហើយសូន្យគឺ: ធាតុដីទៅជាដី ធាតុទឹកទៅជាទឹក ធាតុភ្លើងទៅជាភ្លើង ធាតុខ្យល់ទៅជាខ្យល់ ឥន្ទ្រិយទាំង ៦ សាត់អណ្ដែតទៅក្នុងអាកាស ឥតមានអ្វីខាងមុខអំពីសេចក្ដីស្លាប់ទៅឡើយ ។

ហេតុនោះគ្រូនេះ ឈ្មោះថាជា ឧច្ឆេទទិដ្ឋិ “អ្នកប្រកាន់ថាសូន្យ” ។

(មានត)

ពុទ្ធសាសនា និង ពាហិរសាសនា

លោក ម៉ុញ ឆាគ្រី រៀបរៀង

(តមក)

---

# គ្រិស្តសាសនា

## ១ – លទ្ធិកាតូលិក

សាសនានេះ ជាលទ្ធិមួយដែលកើតឡើងនៅប្រទេសស៊ីរី ដោយសារដើមគំនិតរបស់គណាចារ្យ ១ នាក់ឈ្មោះហ្ស៊េហ្ស៊ូ - គ្រិស្ត (Jésus-Christ = អ្នកប្រោសប្រស់) ។

## ប្រវត្តិហ្ស៊េហ្ស៊ូ - គ្រិស្ត (សង្ខេប)

ហ្ស៊េហ្ស៊ូ - គ្រិស្ត ជាគណាចារ្យមួយដែលកើតឡើងក្នុងរវាង ព.ស ៥៤៣ ជាបុត្ររបស់ស៊ូសែហ្វ និងនាងព្រហ្មចារី ម៉ារី ជាតិក្រស្ត ចាប់កំណើតនៅក្រុងបេត្លេហែម (Bethléhem) ទៀបក្រុងហ្សេរូសាឡេម ក្នុងរាជ្យព្រះបាទហេរ៉ូដ ។ ដើម្បីនឹងរំលឹកដល់ថ្ងៃដែលព្រះហ្ស៊េហ្ស៊ូកើត ពួកគ្រិស្តបរិស័ទ (កាតូលិក) កំណត់យកថ្ងៃ ២៥ ដេសែម្ប្រ៍[១] ជាថ្ងៃបុណ្យមួយសម្រាប់សាសនា ហៅថា បុណ្យណូអែល (Noël) ។

សម័យនោះ មានពួកបោរាណាចារ្យហោរាសាស្ត្រ បាននាំគ្នាមកកាន់ក្រុងហ្សេរូសាឡេម ដើម្បីនមស្ការហ្ស៊េហ្ស៊ូ ដោយសំគាល់

---

១ ថ្ងៃដែលហ្ស៊េហ្ស៊ូ- គ្រិស្តកើត ជាកាលចាប់រាប់គ្រិស្តសករាជតមក ។

ថាជាស្តេចស្វ៊ីហ្វ ព្រោះបានឃើញផ្កាយកំណើតខាងទិសបូព៌ា ។ ដំណឹងនេះជ្រាបដល់ព្រះបាទហេរូដ ទ្រង់ព្រះក្រោធឲ្យស្វែងរកសម្លាប់ហ្សេ-ហ្ស៊ូទារក ប៉ុន្តែរកមិនប្រទះ ដោយស៊ូសែហ្វ និងនាងម៉ារី នាំពង្រត់យកទៅទុកនៅស្រុក អេហ្ស៊ីប្ត (Egypte) តាមបង្គាប់សុបិននិមិត្តរបស់ទេពតាឈ្មោះគាព្រីយេល (Gabriel), ម្យ៉ាងហើយព្រះបាទហេរូដ រឹងរឹតតែខ្ញាល់ជាខ្លាំង ទ្រង់ឲ្យរកផងបុរសពិឃាតពួកទារកក្នុងស្រុកបេត្លេហេម ដែលមានអាយុត្រឹម ២ ឆ្នាំចុះមក ។

ពេលក្រោយមក ព្រះបាទហេរូដទ្រង់ទិវង្គតទៅ, មាតាបិតារបស់ហ្សេហ្ស៊ូបាននាំកូនមកកាន់ភូមិណាសារេថ ឃុំគាលីឡេ ជាស្រុកដើមរបស់ខ្លួនវិញ ។ ដល់កុមារហ្សេហ្ស៊ូ មានអាយុ ១២ ឆ្នាំ មាតាបិតា ក៏បាននាំទៅក្រុងហ្សេរូសាឡេម ដើម្បីធ្វើបុណ្យប៉ាក់ (Pâque) ។ លុះបុណ្យនោះស្រេចហើយ មាតាបិតាស្រាប់តែបាត់កូនរកមិនឃើញ ដោយការច្របូកច្របល់នឹងមហាជនច្រើន, ដល់ពេលល្ងាច ស្រាប់តែក្រឡេកឃើញហ្សេហ្ស៊ូ កំពុងអង្គុយអធិប្បាយក្នុងចំណោមនៃអ្នកប្រាជ្ញកណ្តាលមន្ទីរមួយ ក៏នាំត្រឡប់វិលមកកាន់ភូមិណាសារេថវិញ ។

ដល់អាយុបាន ៣០ ឆ្នាំ ហ្សេហ្ស៊ូបានទទួលនាមបញ្ញត្តិថាជាអ្នកចូលសាសន៍ជាបុត្រព្រះម្ចាស់ស្លូតអំពីហ្សង់-បាប្ទិស្ទ (Jean-Baptiste) នៅមាត់ទន្លេហ្សួរដាំង (Jourdain) នៅវេលានោះគេឃើញមានពន្លឺចាំងមកពីក្នុង

មេឃចំលើក្បាលហ្សេហ្សូហើយឮសូរសព្ទថា "នេះបុត្រសំឡាញ់ខ្ញុំដែលខ្ញុំមានសេចក្តីស្នេហាជាទីបំផុត" ។ ពេលនោះគេយល់ថា គួរិញ្ញាណរបស់ព្រះជាម្ចាស់សួគ៌ចុះមកសណ្ឋិតក្នុងរូបហ្សេហ្សូ ចាំងសូរសព្ទនោះក៏ជាសូរសៀងរបស់ព្រះជាម្ចាស់សួគ៌ទ្រង់ប្រទានពរ ។ ហេតុអស្ចារ្យត្រឹមប៉ុណ្ណោះ ហ្សេហ្សូក៏ឈ្មោះថាបានសំរេចគុណវិសេសហើយ ។

លំដាប់អំពីនោះមក ព្រះហ្សេហ្សូបានចូលទៅរកទីស្ងប់ស្ងាត់ដើម្បីល្បងមើលអស់តាំងពួកបិសាចកផុត , ហើយអត់អាហារបានអស់រវាង ៤០ ថ្ងៃ, លុះចេញអំពីទីនោះមកវិញ ត្រឡប់មកកាន់ឃុំគាលីឡេ តាំងចាប់ផ្តើមប្រកាសសាសនាថ្មី តាមលំដាប់ទូទៅតាំងស្រុកប៉ាឡេ-ស្ទីន ។

របៀបការផ្សាយសាសនានេះ, បើរួបរួមមក, ព្រះហ្សេហ្សូប្រើឧបាយ ២ យ៉ាងគឺ តាំងខ្លួនជាសាស្តាចារ្យទេសនាប្រៀនប្រដៅ និង តាំងជាគ្រូពេទ្យព្យាបាលរោគផ្សេងៗ ឥតយកឈ្នួល ។ មនុស្សជម្ងឺដែលគាត់បានជួយព្យាបាលតាំងអម្បាលម៉ាន ទោះបីពិការពិការគមគាត់ខ្វាក់ខ្វិនគថ្លង់កែងកង់ជើងដៃយ៉ាងណា ក៏គង់ក្លាយទៅជាមនុស្សពូកែរឹងប៉ឹងឡើងបាន សូម្បីមនុស្សដែលទើបនឹងស្លាប់ហើយរវាង ៣-៤ ថ្ងៃ ក៏បែរជាមានជីវិតរស់ឡើងវិញ ហេតុដល់បានមនុស្សតាំងនោះមកជាសាវ័ករបស់ខ្លួនផង ។

ឯសាវករបស់ហ្សេហ្ស៊ូមាន ១២ នាក់គឺពៀរ, អង់ដ្រេ, ហ្សាក់, ហ្សង់, ហ្វីលិប, បារតេលេមី, តូម៉ាស់, ម៉ាត្យឺ, ហ្សាក់, តាដេ, ស៊ីម៉ុងហ្សូដាស់, អ៊ីស្កា-រីយ៉ូត ។ កាលបើព្រះហ្សេហ្ស៊ូមានសាវកដូច្នេះហើយ ទើបហៅសាវកទាំងនោះមកប្រជុំគ្នា ហើយអនុញ្ញាតឲ្យជួយផ្សាយដំណឹងល្អ តាមបែបបទរបស់ខ្លួនតទៅ ។ ឯកិច្ចដែលប្រើនោះ ព្រះហ្សេហ្ស៊ូបានផ្តាំទុកច្រើនយ៉ាងមានដើមថា "ឋានសួគ៌មកជិតហើយ, ត្រូវព្យាបាលពេលគ្រប់យ៉ាងកុំបាច់យករង្វាន់, មិនត្រូវមានមាស-ប្រាក់ក្នុងខ្សែចង្កេះរបស់ខ្លួន, មិនត្រូវមានសម្លៀកបំពាក់ពីរបន្លាស់ឡើងទៅទេ, មិនត្រូវពាក់ស្បែកជើង, មិនត្រូវមានដំបងឈើច្រត់..........." ។

ពួកគ្រិស្តសាវកទាំងនោះ បានទទួលត្រិស្តាប់ទហើយ ក៏ត្រេចរង្កាត់ទៅកាន់ស្រុកតូច-ធំនិគមជនបទ ទាំងតពង្រីកផ្សាយគ្រិស្តសាសនាឮទៅក្នុងប្រទេសស៊ីរីទាំងមូល ។ អាស្រ័យឧបាយទាំង ២ ប្រការនេះហើយ ទើបពួកអ្នកស្រុកស៊ីរីទាំងមូលនាំគ្នាឈូកក្លូកពឹកចុះចូលជាច្រើន ជាហេតុនាំឲ្យពួកហ្វារីស៊ៀន មិនសប្បាយចិត្ត. នាំឲ្យពួករដ្ឋបាលកើតសេចក្តីរង្កៀស. ទើបក្រុមរដ្ឋបាលរិះរកតែឧបាយនឹងចាប់ខ្លួនហ្សេហ្ស៊ូយកទៅប្រហារជីវិត ។

ថ្ងៃមួយជាកាលកម្មរបស់ហ្សេហ្ស៊ូ នាំបណ្តាលឲ្យពួកហ្សូដាស់ជាសាវករបស់ខ្លួនកើតចិត្តកាឃាតព្យាបាទឡើង បានចូលទៅជានាអះ

គាត់ទទួលខុនស្ទីរកចាប់ត្រង់ងន់ផ្ទួនផ្ទាល · ដោយរង្វាន់ប្រហែល ៣០ រៀលប៉ុណ្ណោះ ។ ជួនវេលានោះជាឱកាសបុណ្យប៉ាក់ (Pâque) ព្រះយេស៊ូប្រជុំសាវកទាំង ១២ នាក់ មកលៀងភោជនាហារពេលល្ងាច ជាមួយគ្នា ហើយប្រាប់ថា “បណ្ដាអ្នកទាំងអស់គ្នានេះ មានអ្នកម្នាក់គិតក្បត់ខ្ញុំ” ថាហើយហុចនំប៉័ងចែកទៅឲ្យគ្រប់គ្នារួចថា “អ្នកគ្រប់គ្នាចូរបរិភោគទៅ នេះជាសាច់របស់ខ្ញុំ” រួចហុចស្រាទៅឲ្យទៀតប្រាប់ថា “អ្នកគ្រប់គ្នាផឹកទៅ នេះជាឈាមរបស់ខ្ញុំ...” ។

លុះស្រេចកិច្ចពេលល្ងាចហើយ ព្រះយេស៊ូនាំសិស្សគណទាំងនោះទៅកាន់ភ្នំអូលីវៀរ (Olivier) ។ វេលាយប់នោះជាអវសានកាលរបស់ព្រះយេស៊ូ, យូដាសនាំពួកសេនាទាហានឡើងទៅចាប់បានចងព័យបណ្ដើរនាំមកជូនប៉ុងស៍ពីឡាត់ (Ponce Pilate) ជាទេសាហ្វាយខេត្តយូដេ ដែលប្រជុំទៅដោយក្រុមតុលាការនិងក្រុមតំណាងនីកស្រុកទាំងនោះ ។ ខណៈនោះព្រះយេស៊ូជាបុគ្គលកំព្រា ពួកសាវករត់បោលអស់រលីង នៅសល់តែព្យែរម្នាក់ឯងតាមទៅជាមួយដើម្បីចាំមើលផលបំផុតនៃហេតុការណ៍ ។

មន្ត្រីទាំងនោះរំលោភកាត់ទោសព្រះយេស៊ូថាត្រូវប្រហារជីវិតបង់ ទើបចាត់ប្រើពេជ្ឈឃាដឲ្យនាំទៅកាន់ភ្នំគោលគោត្តា (Golgotha) ជាទីសម្រាប់ពិឃាដនៅជិតក្រុងយេរូសាឡេម ដល់ហើយពួកពេជ្ឈឃាដ

កឺតាប់ព្រះហ្ស៊េហ្ស៊ូឆ្កាងទាំងរស់ឥតត្រាប្រណី ក្នុងពេលជាមួយនឹងចោរប្លន់ ២ នាក់ ដែលមានទោសគួរដល់ការឆ្កាង នៅសងខាង (ឆ្វេងស្ដាំ) ព្រះហ្ស៊េហ្ស៊ូ ។

មុខគួរឲ្យអនិច្ចាដល់រូបព្រះហ្ស៊េហ្ស៊ូ ! កាលបើត្រូវទុក្ខវេទនាគ្រប់សង្កត់ទៀបផុតរលត់ជីវិតប្រិយយ៉ាងនេះហើយ ចេះតែស្រែកហៅព្រះជាម្ចាស់សូមឲ្យជួយ ពុសូរគ្រលួចឡើងថា “ព្រះម្ចាស់ខ្ញុំ, ព្រះម្ចាស់ខ្ញុំ, ហេតុអ្វីក៏ទ្រង់បោះបង់ចោលខ្ញុំ” (Eli, Eli, lamma sabachthani) ។ នៅទីបំផុតសូរសំរែកនេះ, ព្រះហ្ស៊េហ្ស៊ូក៏ផុតរលត់អស្សាសបស្សាសៈ នៅវេលារសៀលម៉ោង ៣ ក្នុងថ្ងៃនោះក្នុងរាងអាយុ ៣៣ ឆ្នាំ ។ ដល់វេលាល្ងាច, មានកុដុម្ពីម្នាក់ឈ្មោះហ្សូសែហ្វ បានចូលមកសុំរូបសពព្រះហ្ស៊េហ្ស៊ូអំពីប៉ុងស៍ប៉ីឡាត់យកទៅបញ្ចុះទុកនៅក្បែរទីនោះ ។

មានដំណាលថា កាលព្រះហ្ស៊េហ្ស៊ូរស់នៅឡើយ បានផ្ដាំទុកថា ខ្លួននឹងមានជីវិតឡើងវិញក្នុងថ្ងៃទី ៣ អំពីថ្ងៃមរណកាល ។ ហេតុនេះហើយបានជាមានទាហានខ្លះ ពួកស្ត្រីជាសិស្សគណរបស់គាត់ខ្លះ នៅចាំយាមក្នុងទីនោះ ដើម្បីចាំពិនិត្យមើលហេតុកើតតាមបណ្ដាំព្រះហ្ស៊េហ្ស៊ូ ។

លុះគ្រប់កំណត់កាលវេលា, ព្រះហ្ស៊េហ្ស៊ូផុះឡើងចាកផ្នូរហើយហោះឡើងទៅកាន់ភ្នំ គាល្វែ ជាទីប្រជុំនៃសាវកដែលបានសន្មតទុកពីថ្ងៃមុន ។ ដើម្បីនឹងរឭកដល់ការរស់ឡើងវិញនៃព្រះហ្ស៊េហ្ស៊ូនេះ

ទើបពួកកាតូលិកនាំគ្នាធ្វើបុណ្យប៉ាក់ (Pâque) ទុកជាទំនៀមរៀងរាបមក ។

ព្រះហ្ស៊េហ្ស៊ូបានរស់ឡើងហើយ ឋិតនៅក្នុងលោកនេះអស់ ៤០ ថ្ងៃទៀត, ក្នុងថ្ងៃទីបំផុត ៤០ ថ្ងៃនេះ ព្រះហ្ស៊េហ្ស៊ូបានប្រជុំសាវកទាំង ១២ នាក់នៅកំពូលភ្នំអូលីវ៉េយេរ ហើយផ្ដាំទុកជាបច្ឆិមទុកទថា "អ្នកទាំង-ឡាយទៅចុះ ចូរអ្នកបង្រៀនជនជាតិទាំងពួង ហើយញ៉ាំងជនទាំងនោះឲ្យចូលសាសនាដោយនាមរបស់បិតា របស់បុត្រនឹងព្រះវិញ្ញាណ, ញ៉ាំងជនទាំងនោះឲ្យប្រព្រឹត្តតាមបញ្ញត្តិដែលខ្ញុំបានបញ្ញត្តហើយ កិច្ចនេះឯងឈ្មោះថាខ្ញុំបានឋិតនៅជានិច្ចជាមួយអ្នករាល់គ្នា ដរាបដល់កាលទីបំផុតនៃលោក" ។

លុះចប់បច្ឆិមទុកទនេះហើយ, ព្រះហ្ស៊េហ្ស៊ូក៏ហោះទៅកាន់ឋានសួគ៌ ហើយចូលទៅអង្គុយទៀបខាងស្ដាំនៃព្រះម្ចាស់សួគ៌ជាបិតា ។ ដើម្បីនឹងរំឭកដល់ថ្ងៃដែលព្រះហ្ស៊េហ្ស៊ូហោះទៅកាន់ឋានសួគ៌នេះឯង ពួកគ្រិស្ដបរិស័ទ្យនាំគ្នាធ្វើបុណ្យអសង់ស្យុង (Ascension) ជាទំនៀមតមក ។

ក្រោយថ្ងៃដែលព្រះហ្ស៊េហ្ស៊ូឡើងទៅកាន់សួគ៌លោកបាត់ទៅ, មានដំណាលថា: ព្រះវិញ្ញាណមានអាការដូចជាអណ្ដាតភ្លើងចុះពីឋានសួគ៌មកសណ្ឋិតក្នុងរូបសាវកទាំងនោះៗ ទើបឈ្មោះថាបានពេញលក្ខណៈជាសាវក ហើយនាំគ្នាប្រកាសគ្រិស្ដសាសនាតរៀងមក ។ អាស្រ័យ

ហេតុនេះ ទើបពួកគ្រិស្តសាសនិកជននាំគ្នាធ្វើបុណ្យបង់ទីកូត៍ Pentecôte) ដើម្បីទុករំលឹកដល់ថ្ងៃដែលព្រះវិញ្ញាណចុះពាកស្ថានសួគ៌ ។

## បញ្ញត្តិរបស់ព្រះម្ចាស់សួគ៌ ១០យ៉ាង

១— ត្រូវគោរពបូជាព្រះម្ចាស់សួគ៌(១)

២— មិនត្រូវប្រមាទព្រះនាមព្រះអង្គឬយកមកស្បថស្បែលេង

៣— ថ្ងៃអាទិត្យត្រូវញ៉ាំងខ្លួនឲ្យបរិសុទ្ធ(២)

៤— ត្រូវគោរពមាតាបិតា(៣)

៥— មិនត្រូវធ្វើមនុស្សឃាត(៤)

៦— កុំប្រព្រឹត្តទុច្ចរិត

៧— កុំគប្បីកាន់យកទ្រព្យអ្នកដទៃ

---

១ ពួកកាតូលិកជឿថា ព្រះមានតែមួយគឺព្រះម្ចាស់សួគ៌ (Dieu) មានជីវិតរស់នៅជានិច្ច មិនចេះផុត ជាអ្នកបង្កើតពិភពលោក ព្រមទាំងធម្មជាតិគ្រប់យ៉ាងត្រឹម ៦ ថ្ងៃប៉ុណ្ណោះ គឺ ថ្ងៃទី ១ បង្កើតពន្លឺគឺព្រះអាទិត្យ និងព្រះចន្ទ, ថ្ងៃទី ២ មេឃនិងដី, ថ្ងៃទី ៣ សមុទ្រ, ថ្ងៃទី ៤ ផ្កាយ, ថ្ងៃទី ៥ បក្សីបក្សា មច្ឆាមច្ឆា, ថ្ងៃទី ៦ ទើបបង្កើតមនុស្សគូបុរសស្ត្រី គឺអាដាមនិងនាងអែវ (Adam, Eve) ។ ២ ថ្ងៃអាទិត្យជាថ្ងៃព្រះ ត្រូវញ៉ាំងខ្លួនឲ្យបរិសុទ្ធ គឺត្រូវបញ្ឈប់កិច្ចការផ្សេងក្រៅអំពីកិច្ចសាសនា ។ ៣ ត្រង់នេះសូម្បីអ្នកធំផងក្រៅអំពីមាតាបិតា ក៏ត្រូវគោរព ព្រមទាំងជួយបំពេញកិច្ចការសម្រាប់ជាតិភូមិ ។ ៤ ត្រង់នេះសូម្បីខ្លួនឯង ក៏មិនត្រូវសម្លាប់, តែបុគ្គល ៣ ពួក គឺពួកទ័ពបច្ចាមិត្ត មនុស្សមានទោសត្រូវប្រហារជីវិត និងចោរដែលបម្រុងមកប្រហារជីវិតខ្លួន ត្រូវសម្លាប់បាន ។

៨- កុំពោលពាក្យកុហក

៩- ត្រូវកំចាត់សេចក្ដីប្រាថ្នាលាមក

១០- មិនត្រូវរំពៃរកទ្រព្យអ្នកដទៃ ។

## វិធីចូលសាសន៍

វិធីនេះប្រកបដោយអត្ថ ២ គឺ ទឹក និងវិញ្ញត្តិរបស់សង្ឃរាជ ។ សាមីខ្លួនបរិសុទ្ធអ្នកចូលសាសន៍ ត្រូវចូលទៅរកសង្ឃរាជឲ្យស្រោចទឹក ( សុទ្ធ ) លើក្បាលហើយប្រសិទ្ធិឲ្យថា "ខ្ញុំប្រសិទ្ធិអ្នកដោយនាមរបស់ បិតា និងបុត្រនិងព្រះវិញ្ញាណ" ។ ដោយកិច្ចប៉ុណ្ណេះ បុគ្គលនេះឈ្មោះថាបានជាបុត្ររបស់ព្រះជាម្ចាស់ ហើយបានរួចពាកបាបសព្វយ៉ាង ដែលខ្លួនបានធ្វើមកហើយតាំងអំពីកំណើត និងបានទៅកើតក្នុងឋានសួគ៌ ។

## ពិធីលាងបាប

បាបចែកចេញជា ២ យ៉ាងគឺ បាបធ្ងន់និងបាបស្រាល ។ បាបធ្ងន់ បានដល់កំហុសដែលកើតឡើងព្រោះការប្រព្រឹត្តកន្លងបញ្ញត្តិយ៉ាងធ្ងន់ៗ របស់ព្រះជាម្ចាស់សួគ៌ប្រកបដោយចេតនាក្នុង; បាបស្រាលបានដល់ កំហុសដែលប្រព្រឹត្តកន្លងបញ្ញត្តិយ៉ាងស្រាលៗ របស់ព្រះជាម្ចាស់ ឬក៏ កន្លងបញ្ញត្តិយ៉ាងធ្ងន់ ប៉ុន្តែមិនប្រកបដោយចេតនាក្នុង ។ បាបទាំង ២ ប្រការនេះកើតឡើងដោយសមុដ្ឋាន ៤ គឺ ការគិត, ការនិយាយ, ការធ្វើ និងសេចក្ដីប្រហែសធ្វេស ។

បុគ្គលដែលប្រកបដោយទោសស្រាល មិនបាច់ធ្វើពិធីលាងបាបក៏បាន, បើមានទោសធ្ងន់ត្រូវធ្វើពិធីលាងបាប ព្រោះជាទោសអាចឲ្យធ្លាក់ទៅនរក ។ ឯពិធីលាងបាបនោះ អ្នកប្រព្រឹត្តកន្លងត្រូវទៅសំដែងទោសនោះក្នុងវិហារចំពោះលោកសង្ឃ (Prête) ដើម្បីឲ្យអត់ទោសឲ្យ ។ ពិធីនេះ គ្រិស្តបរិស័ទត្រូវធ្វើយ៉ាងតិចក្នុងមួយឆ្នាំម្ដង ។

## លោកខាងមុខ

លទ្ធិនេះប្រកាន់ថា លោកខាងមុខមាន ៣ គឺ ស្ថានសួគ៌, ស្ថាននរក, និងស្ថានសម្រាប់ប្រព្រឹត្តតបៈ ។ ស្ថានសួគ៌និងស្ថាននរកទៀត, បុគ្គលដែលស្លាប់ទៅ ព្រលឹងរបស់បុគ្គលនោះ ត្រូវទៅឲ្យជួបនឹងព្រះម្ចាស់សួគ៌ឲ្យទ្រង់វិនិច្ឆ័យសេចក្ដីឲ្យ; បើខ្លួនបរិសុទ្ធ ត្រូវបានទៅកើតស្ថានសួគ៌, បើមានទោសធ្ងន់ ត្រូវទៅកើតក្នុងស្ថាននរក; បើមានទោសស្រាល ព្រះម្ចាស់សួគ៌ដាក់ទណ្ឌកម្មឲ្យទៅកាន់ទីមួយសម្រាប់ប្រព្រឹត្តតបៈញុំាងខ្លួនឲ្យបរិសុទ្ធិ ហើយនឹងបានទៅកើតស្ថានសួគ៌នៅវេលាក្រោយដែលរួចទោសហើយ ។ បុគ្គលដែលបានទៅកើតក្នុងស្ថានសួគ៌ក្ដី នរកក្ដីលែងប្ដូរប្រែប្រួលទៅកាន់ទីណាទៀត ។

ដល់ទីបំផុតនៃលោកនេះ មនុស្សដែលស្លាប់ទៅអម្បាលម៉ាន នឹងរស់ឡើងវិញ ។ នៅវេលានោះ ព្រះយេហ្ស៊ូនឹងចុះពាកសួគ៌មកកាន់ពិភពលោកនេះម្ដងទៀត ដើម្បីនឹងវិនិច្ឆ័យសេចក្ដីឲ្យសត្វលោកជាកិច្ចទីបំផុត ។

(មានត)

ពុទ្ធសាសនា និង ពាហិរសាសនា

លោក មុិញ - ផ៉ាគ្រី រៀបរៀង

(តមក)

---

# គ្រិស្តសាសនា

## ២ – លទ្ធិប្រូតេស្តង់ត៍

សព្ទនេះបានសេចក្តីថា "លទ្ធិទទឹងទាស់" ឬថា "លទ្ធិកែទម្រង់" (Réforme) ជាឈ្មោះនិកាយដែលបែកចេញមកអំពីនិកាយកាតូលិក ក្នុងរវាង ព. ស. ២០៦០, គ. ស. ១៥១៧ ដោយសារពាហិរបព្វជិតជាតិអល្លឺម៉ង់មួយរូបឈ្មោះលូថេរ[១] (Luther) ជាសាស្ត្រាចារ្យសាលាវិទ្យាល័យវិត្តិនតេម្បេរ ប្រទេសអល្លឺម៉ាញ ។

ហេតុដែលនាំឲ្យបែកចេញជានិកាយថ្មីនេះឡើង មកអំពីទោសនៃការប្រព្រឹត្តិផ្តេកផ្តាសខុសពាក្យគម្ពីរប៊ីប្លិ៍ (Bible) នៃគណៈសង្ឃអលដ្ឋ មានសម្តេចព្រះសង្ឃរាជគ្រង់រោមជាដើម ។ តាមសេចក្តីដំណាលថា: សង្ឃរាជនោះមានការចិញ្ចឹមជីវិតដូចគ្រហស្ថ ហើយខ្វះគាប់ចិត្តយ៉ាងណា ក៏ប្រជុំគណៈសង្ឃមកបញ្ញត្តសិក្ខាបទយ៉ាងនោះ តាំងបញ្ញត្តិថ្មីដែលសង្ឃរាជឬគណៈសង្ឃបញ្ញត្តតាំងអម្បាលម៉ាន, គ្រិស្តបរិសទ្យធ្លាប់ចុះចិត្ត

---

១ ម៉ាតិន លូថេរ (Martin-Luther) កើតនៅស្រុកអឺស្លេបេន គ. ស. ១៤៨៣ បែកបាក់ពួករ៉ូម៉ាំង - កាតូលិក (នៅវេលាប្រកាសចុះទោស) គ. ស. ·៥១៧ ក្នុងដំណាក់សង្ឃរាជ ឡេអុង ទី ១០ ក្នុងវាក្យព្រះបាទសារល្ហេកាំង ដែលទ្រង់ឲ្យកាត់ទោស បញ្ជូនយកខ្លួនបណ្តេញចាកសាសន៍នៅសាលាវិនិច្ឆ័យ ក្រុងវ៉ម៉ិ គ. ស. ១៥២១ ។

ជឿស៊ប់ថាជាបញ្ញត្តិរបស់ព្រះម្ចាស់សួគ៌ គឺព្រះជាម្ចាស់សួគ៌ឲ្យបញ្ញត្ត ម៉្លោះហើយជាឱកាសឲ្យសង្ឃរាជ ឬគណៈសង្ឃបញ្ញត្តតាមសេចក្តីយល់ឃើញថាស្រួល ។

លទ្ធិកាតូលិក យើងធ្លាប់ដឹងមកហើយថា មានពិធីលាងបាប ។ ឯលទ្ធិនេះ បើបុគ្គលមានទោសល្មម ក៏អាចរួចទោសបានដោយពិធីសូត្រមន្តអង្វរគេសូមខមាទោសនឹងព្រះជាម្ចាស់; បើបុគ្គលមានទោសធ្ងន់ត្រូវតែនៅបរិវាសកម្ម ឬដើរធុតង្គរុក្ខមូល ទៅនមស្សការកន្លែងព្រះហ្ស៊ីហ្ស៊ូប្រសូត ជាកិច្ចទណ្ឌកម្ម ទើបរួចទោសបាន ។

ថ្ងៃមួយជាហេតុនាំឲ្យផ្ទុះចេញជាលទ្ធិនេះឡើង, សម្តេចព្រះសង្ឃរាជក្រុងរោមចង់សាងវិហារវត្ត (Saint-Pierre) ឲ្យល្អឆើតជាប់វត្តតាំងពួងឲ្យសមស័ក្តិរបស់ខ្លួន តែនឹងរកបច្ច័យសម្រាប់កសាងតាមបំណងរបស់ខ្លួនដូច្នោះពុំបាន ទើបកែប្រែបញ្ញត្តិដើមថាៈ បុគ្គលដែលមានទោសធ្ងន់ៗយ៉ាងណា ក៏អាចរួចទោសបានដោយការបំណាយប្រាក់កសាងវិហារនេះ (មិនបាច់នៅបរិវាសកម្ម ឬដើរធុតង្គរុក្ខមូលដូចមុនទេ) ។

រឿងនេះឯង ជាសេចក្តីអបយសសម្រាប់សាសនា នាំឲ្យលោកអាចារ្យលូថេរឆ្ងល់ក្នុងចិត្តស្ងៀមមាត់មិនកើត ទើបប្រជុំពួកអាចារ្យមកពិគ្រោះគ្នាអំពីរឿងនេះជាច្រើនលើក ហើយមូលមតិគ្នាសំរេចសេចក្តីថា មិនត្រូវប្រតិបត្តិតាមបញ្ញត្តិរបស់សម្តេចព្រះសង្ឃរាជឡើយ ។ ដំណឹង

នេះមិនស្ងាត់ឈ្ងាត់ ក៏ត្អូញទៅដល់សម្តេចព្រះសង្ឃរាជក្រុងរោមៗហៅលោកអាចារ្យលូថេរមកដាស់តឿនឲ្យលះបង់ទិដ្ឋិផ្ទុយពាស់នោះចោលចេញ តែអាចារ្យលូថេរមិនព្រមលះសោះ សម្តេចព្រះសង្ឃរាជទើបធ្វើញត្តិយកកម្មបណ្តេញលូថេរចេញ ។ តាំងអំពីកាលនោះមក លូថេរប្រកាសសេចក្តីយល់របស់ខ្លួនដែលផ្ទុយពាស់នឹងសង្ឃរាជ ៩៥ ខ ហើយចាប់ប្រែគម្ពីរប៊ីប្ល៍ភាសាឡាតាំងមកជាភាសាអ្នកស្រុកសាមញ្ញ ដើម្បីនឹងសំដែងឲ្យឃើញថាសេចក្តីពិតសម្រាប់គ្រិស្តសាសនានោះត្រឹមណា រួចហើយបោះពុម្ពផ្សាយសាធារណ៍ទូទៅ ។ ជនដែលមានសៀវភៅប្រែនេះក្នុងដៃ សឹងយល់ត្រូវស្របតាមលូថេរទាំងអស់ គឺយល់ឃើញថាលទ្ធិសម្តេចព្រះសង្ឃរាជជាលទ្ធិបុកណានោះ ក្លាំងក្លាត់ខុសបាកគម្ពីរប៊ីប្ល៍ច្រើនណាស់ ម៉្លោះហើយលទ្ធិថ្មីនេះចេះតែផ្សាយឥទ្ធិពលកាន់តែធំទូលាយឡើង រហូតដល់ផុតអំណាចសង្ឃរាជក្រុងរោមនឹងស្តេចផែនដីការពារលែងបាន ។

ឯលទ្ធិថ្មីដែលលូថេរប្រកាសឡើងនោះដូច្នេះ: លូថេរប្រកាន់ទុកនូវគោលធំៗ សម្រាប់គ្រិស្តសាសនាទាំង៣គឺ ត្រៃឯកានុភាព (Trinité)១, បាប គឺកំហុសចំពោះព្រះ (Chute)១, និងការលោះបាប (Rédemption)១ ហើយនឹងធម្មជាតិ ២ យ៉ាងរបស់ព្រះគ្រិស្ត (ស្រានឹងនំប៉័ង) ។

លូថេរបដិសេធឋានសម្រាប់ប្រព្រឹត្តតបៈញុំាងខ្លួនឲ្យបរិសុទ្ធ, ការពឹងពាក់ព្រះអរហន្ត, ការលោះបាបចំពោះបុគ្គលម្នាក់ៗ ឯង; បដិសេធពិធី

បុណ្យផ្សេងៗ ទុកតែពិធីបញ្ចូលសាសន៍ និងពិធីមហាសុទ្ធិ; មិនឲ្យមានអាពាមសម្រាប់ពួកនាងជី, ពួកបព្វជិតត្រូវមានប្រពន្ធបាន, ប្រកាន់ថា វត្ថុដែលល្អដែលសំខាន់បំផុតរបស់ព្រះយេហ្ស៊ូគ្រិស្ត នៅក្នុងនំបុ័ងនិងស្រាទំពាំងជូរ ។ មានសេចក្ដីយល់ ២ ប្រការទៀតដែលជាគោលធំ គឺយល់ថា សេចក្ដីបរិសុទ្ធិអាស្រ័យដំនឿនឹងព្រហ្មលិខិត ។

លូថេរនឹងពួកប្រូតេស្តង់យល់ថា: ដំនឿសឹងពិសេសលើសកិច្ចការ, បុគ្គលដែលជឿតែដែលគួរជឿនឹងរួចចាកទុក្ខបាន ។ ព្រហ្មលិខិត: ព្រះជាម្ចាស់សួគ៌ទ្រង់ជ្រើសរើសគេបុគ្គលតាមដែលទ្រង់ប្រាថ្នា មិនមែនសំរេចតាមបំណងរបស់មនុស្សយើងទេ ។

## សាសនាអិស្លាម

សាសនាអិស្លាម ជាលទ្ធិមួយដែលកើតឡើងក្នុងប្រទេសអារ៉ាប់ ដោយស្នាដៃឬគំនិតរបស់គ្រូម្នាក់ឈ្មោះ “មោហាម័ទ” ។ លទ្ធិនេះដែលបានឈ្មោះដូច្នេះ ដោយសំគាល់សេចក្ដីថា “ជំនឿស្រោចស្រង់សត្វ” ។

## ប្រវត្តិមោហាម៉ទ (សង្ខេប)

មោហាម័ទ ជាសាស្ដាចារ្យរបស់ជនជាតិអារ៉ាប់, កើតនៅស្រុកមេក: (Mecque) រាវ ព. ស. ១១១៣, គ. ស. ៥៧០, ជាពូជពង្សវង្សត្រកូលរបស់ហាស្ហេម (Haschem) ដែលជាវង្សមានឈ្មោះល្បីល្បាញទូទៅក្នុងពួកកូរេស្ហ (Koréichite), កំព្រាតាំងអំពីតូច ជីតាយក

មកចិញ្ចឹម, តមកទៀតក្រោយអស់អំពីជីតាទៅ បានទៅនៅអាស្រ័យនឹងឪពុកមា ឈ្មោះអាប៊ូតាលេប (Abou-Talep) មានការចិញ្ចឹមជីវិតដោយពាណិជ្ជកម្ម, មានលក្ខណៈជាបុគ្គលមានសេចក្ដីក្លាហានអង់អាច, មានចិត្តសាធារណ៍ ចិត្តទូលាយ, បាននាងគដិជៈជាស្ត្រីមេម៉ាយមានទ្រព្យសម្បត្តិស្ដុកស្ដម្ភជាភរិយា ។ អាស្រ័យហេតុនេះ ទើបបណ្ដាលឲ្យមោហាម័ទមានឥទ្ធិពល មានអានុភាពកាន់តែធំទូលាយឡើងក្នុងជាតិរបស់ខ្លួន ។

ដល់មកអាយុ ៤០ ឆ្នាំ មោហាម័ទមិនទាន់សំរេចកិច្ចការពិសេសអ្វីមួយ ដែលអាចឲ្យគេចាយបានថាជាមហាបុរសនៅឡើយ ។ សម័យមួយនោះ គាត់ដកថយទៅរកកន្លែងស្ងប់ស្ងាត់ ដើម្បីស្ញឹងស្មាធិចំរើនមេត្តាភាវនា ។ រាត្រីមួយ គាត់នៅសម្ងំក្នុងរូងភ្នំហិរ៉ា, តាមពង្សាវតារអាក់ប៊ែនិយាយថា: មានទេវតាចុះមកហើយត្រដាងក្បួនបង្ហាញប្រាប់ថា "ឯងមើលទៅ" ។ មោហាម័ទប្រកែកថា "ខ្ញុំមិនចេះអានទេ" ។ ទេវតានោះក៏ចាប់សក់លើកក្បាលទន្ទិចផ្ទប់ទៅលើផែនដីអស់វារៈបីដង ហើយប្រាប់ម្ដងទៀតថា "អានក្បួននេះទៅ សុទ្ធតែជាព្រះនាមព្រះជាម្ចាស់ដែលបានបង្កើតវត្ថុគ្រប់យ៉ាង" ។ ម្ដងនេះ មោហាម័ទអានបាន ហើយឮសូរសំឡេងប្រាប់មកទៀតថា "អ្នកឯងជាសាវ័ករបស់ព្រះជាម្ចាស់ហើយ" ។

តាំងអំពីកាលនោះមក មោហាម័ទបានឡើងនាមថា "នបី" សំគាល់ខ្លួនថា "សព្វញ្ញូ" ចាប់ផ្ដើមប្រកាសសាសនាថ្មី ដែលខ្លួនឲ្យឈ្មោះថា

ឥស្លាម "ជំនឿស្រោចស្រង់សត្វ" ។ បុគ្គលដែលមានជំនឿពិតៗក្នុងសាសនានេះបាននាមថា មុស៊ុលម៉ាន (ឥស្លាមសាសនិកជន ឬ ឥស្លាមិកជន) ។ ពួកនេះដំបូងមានចំនួនតិចទេ តអំពីពេលនោះរវាង ៣ ឆ្នាំ មោហាម៉េទទើបតែនឹងញុំាងភរិយារបស់ខ្លួននឹងអាលីដែលជាបងប្អូនជីដូនមួយ ហើយនឹងខ្ញុំកំដររបស់ខ្លួន ព្រមទាំងអ្នកស្រុកមេកៈខ្លះឲ្យចូលសាសនាបាន ។

ដល់មករវាង ព. ស. ១១៥៧, គ. ស. ៦១៤ មោហាម៉េទបានប្រជុំគណៈបាមោក្ខបុគ្គល ដែលជាមេពួកមេក្រុមរបស់ខ្លួនហើយសួរថា "បណ្ដាអ្នកទាំងអស់គ្នា អ្នកណាអាចធ្វើជាបងប្អូនរបស់ខ្ញុំ — ជាមេទ័ពរបស់ខ្ញុំ — ជាសេនាបតីរបស់ខ្ញុំ? ។

អាលីស្ទុះក្រោកក្លួតឡើងឆ្លើយតបថា "ខ្ញុំអាចទទួលរ៉ាប់រងបាន បើមាននរណាមួយរឹងទទឹងនឹងលោក ខ្ញុំនឹងដាច់កាច់ធ្មេញ នឹងឆ្កៀលភ្នែក នឹងវះពោះ នឹងបំបាក់ជើងហោល" ។

លទ្ធិថ្មីនេះ នាំឲ្យផ្ទុយទាស់ដល់អ្នកទាំងពួងជាខ្លាំង បណ្ដាលឲ្យមានគ្រោះថ្នាក់នឹងសេចក្ដីទោមនស្សដល់ពួកកុរេស្ឆជាច្រើន ។ ហេតុនោះ ទើបនាំឲ្យមោហាម៉េទមានទុក្ខទោសគួរដល់សេចក្ដីស្លាប់ ក៏ភៀសខ្លួនរត់ចេញពីស្រុកមេកៈ ទៅនៅស្រុកអ៊ីអាគ្រេប ដែលខ្លួនឲ្យឈ្មោះថា ម៉េឌីន (Médine) សំគាល់សេចក្ដីថា ក្រុងរបស់មោហាម៉េទ ។

ការរត់ទៅនេះ ជាកិច្ចសំខាន់ក្នុងពង្សាវតារអ៊ីស្លាមិកនិកាយ តាំងជាកាលចាប់កប់មោហាម័ទសករាជតាំងពីនោះមកផង (១៦ ស៊ូយេត៦២២) ។

មោហាម័ទនៅក្នុងទីនោះ មិនយូរប៉ុន្មានក៏តាំងប្រជុំអស់មេក្រុមរបស់ខ្លួនបង្កើតជាក្បួនទ័ពលើកចេញមកវាយពួកកូរេស្ស ត្រាតែមានជ័យជំនះ ហើយបានជាសាស្ដាចារ្យនៅស្រុកមេក:, តមកយកបានក្នុងវិហារ "កាអាបា" ដែលជាទីបូជនីយស្ថានសម្រាប់គោរពបូជានៃពួកអារ៉ាប់ទូទៅ ហើយតាំងបានបំផ្លាញរូបសម្រាប់គោរពក្នុងទីនោះអស់ ៣០០ រូប ហើយនិយាយថា "សេចក្ដីពិតមកដល់ហើយ សេចក្ដីកុហកបូរសាបសូន្យទៅ" ។

ក្នុងរវាងពីរឆ្នាំមុនទីបំផុតអាយុរបស់មោហាម័ទ ។ បានផ្សាយសាសនាបញ្ចុះបញ្ចូលពួកអារ៉ាប់បានអស់ ។ ក្នុង ព.ស. ១១៧៤, គ.ស. ៦៣២ មានពួកអ៊ិស្លាមិកបរិសទ្យរាប់សែននាំគ្នាទៅគោរពបូជានៅក្រុងមេក: ។ ក្នុងឆ្នាំនេះ សាស្ដាចារ្យមោហាម័ទដឹងខ្លួនថាជិតដល់មរណកាលហើយ ទើបប្រកាសថា "បើខ្ញុំបានវាយបង្អូនខ្ញុំណាមួយ ឲ្យគេវាយខ្ញុំវិញចុះ, បើខ្ញុំនៅជំពាក់បំណុលញាតិណាមួយ នេះនែប្រាក់សម្រាប់សង" ។ ខណៈនោះមានជំណាលថា: មានបុរសម្នាក់មកទារប្រាក់ចំនួន ២ – ៣ រៀល ។ មោហាម័ទសង់ភ្លាម ដោយសេចក្ដីត្រេកអរថានឹងបានរួចបំណុលក្នុងលោកនេះនឹងលោកខាងមុខ ។

# គម្ពីរកោរ៉ាន (គួអាន)

សាសនាមោហ្ម័ទ មាននៅក្នុងផ្ទៃនៃគម្ពីរកោរ៉ានជាក្បួនសាសនា ដែលអ៊ិស្លាមិកនិកាយនិយមរាប់អានថាជាគម្ពីរដើម ដូចជាគម្ពីរប៊ីប៍ក្នុងគ្រិស្តសាសនា ឬគម្ពីរព្រះត្រៃបិដកខាងពុទ្ធសាសនារបស់យើង ។

គម្ពីរកោរ៉ាននេះមានលទ្ធិសាសនា, បញ្ញត្តិ, ច្បាប់ ដែលមោហ្ម័ទបានសំដែងទុកដោយកិច្ចការផ្សេង ៗ ។ គេបានចារឹកទុកដោយគោរពក្នុងស្លឹករឹត: តមកមានមោហ្ម័ទសាវ័កម្នាក់ឈ្មោះកាលីហ្វ អាប៊ូ-បាករ បានស្រង់ប្រមូលរួបរួមចារឹកចងទុកជាគម្ពីរកោរ៉ានឡើង ។

## លទ្ធិមោហ្ម័ទ

ក្នុងគម្ពីរនេះ មានសេចក្តីពន្យល់ថា ព្រះមានតែមួយគឺ ព្រះអាឡា, មោហ្ម័ទគ្រាន់តែជាទេវទូត (របស់ព្រះអាឡា), ព្រលឹង (វិញ្ញាណ) មិនចេះស្លាប់, ជាតិមុខនឹងត្រូវទទួលយកផលនៃសេចក្តីល្អនិងទោសនៃសេចក្តីអាក្រក់ពុំខាន ។

គោលដែលសំខាន់បំផុតក្នុងសាសនានេះមាន ៣ យ៉ាងគឺ: ការសូត្រមន្ត ១ ការអត់អាហារ ១ និងការឲ្យទាន ១ ។ អ៊ិស្លាមិកជនយល់ថា ការសូត្រមន្ត ជាកិច្ចឲ្យមានដំណើរទៅរកព្រះជាម្ចាស់បានពាក់កណ្តាលផ្លូវ, ការអត់អាហារ ឈ្មោះថាធ្វើដំណើរឲ្យបានដល់ទៅមាត់ទ្វារឋានសួគ៌, ការចែកទាន ឈ្មោះថាបានញុំាងខ្លួនឲ្យចូលទៅដល់ក្នុងឋានសួគ៌ ។ (ម.ឧត)

### ពុទ្ធសាសនា និង មហាសាសនា

## លោក ម៉ុញ-ណាគ្រី រៀបរៀង

(ត-ចប់)

---

### សាសនាសិន្តូ

ពាក្យថា "សិន្តូ" សំគាល់សេចក្តីថា "វិថីផ្លូវរបស់ព្រះជាម្ចាស់"ៗ

សាសនានេះ កើតឡើងក្នុងប្រទេសជប៉ុន ។ គោលសំខាន់របស់សាសនានេះគឺ ការបូជាធម្មជាតិ និងបូជាបុព្វបុរស ។ ឯបុព្វបុរសសំខាន់បំផុតគឺស្តេចម្ចាស់ផែនដី, ព្រោះសាសនានេះប្រដៅគ្នាថា ប្រទេសជប៉ុនជាបំណែករបស់ដួងព្រះអាទិត្យ ដែលផ្ទុះពេយកាយចុះមកជាកោះតូច ៗ, តមកព្រះអាទិត្យបានប្រទានគូបុរសស្ត្រីជាដំបូងគឺព្រះភជានិងព្រះភជននី ទើបកើតជាកូនតួនជាចៅជាតិជប៉ុនរៀងមកដល់សព្វថ្ងៃនេះ ។

សេចក្តីស្អាតជាកិច្ចធំបំផុតសម្រាប់សាសនានេះ ព្រោះមានសេចក្តីបញ្ញត្តិសម្រាប់សាសនាបង្គាប់ថា ការចូលទៅជិតទីបូជារបស់សិន្តូត្រូវងូតទឹកសំអាតកាយឲ្យស្អាតសិន, ការចូលទៅជិតមនុស្សស្លាប់ក៏ដូចគ្នាទាំងត្រូវសំអាតចិត្តផង ។

មួយទៀតសាសនាសិន្តូជាសាសនាប្រដៅឲ្យជឿថា វិញ្ញាណជាវត្ថុមិនស្លាប់ ហេតុដូច្នេះការស្លាប់ក៏ទុកដូចជាផ្លាស់សម្លៀកបំពាក់ជាថ្មី និងមានឋានៈរិតតែវិសេសឡើង ព្រោះជាទីគោរពបូជានៃជនានុជនទូទៅ ។

ហេតុនេះហើយបានជាកូនប្រទេសជប៉ុន មានវិធី "ហារាគិរី" គឺវិធីអត្តវិនិបាតកម្ម (សម្លាប់ខ្លួន) ដែលគេរាប់អានទូទៅថាជាកិច្ចប្រសើរសម្រាប់លាងបាប ជាកិច្ចសំដែងសេចក្ដីសុចរិតសត្យវាទីឲ្យជាក់ស្ដែង ។

កិច្ចនេះត្រូវធ្វើចំពោះមុខប្រជាជន មិនមែនលបលាក់ធ្វើដោយស្ងាត់ៗនោះទេ ។ ឯពិធីដែលត្រូវធ្វើនោះ ដំបូងសាមីរូបដែលដាច់ចិត្តត្រូវពាក់អាវពិធីសម្រាប់ត្រកូលកល់ត្លា ហើយចូលទៅអង្គុយមុខតុះពិធីដែលធ្វើពីឈើពណ៌ស ដែលមានដាក់កាំបិតនៅលើនោះ ។ កាំបិតនោះមានខ្នាតប្រវែង ៩ ធ្នាប់ ហើយរុំដោយក្រដាសពណ៌សច្រើនជាន់ទុកឲ្យនៅសល់តែចុងស្រួច ទើបយកកាំបិតនោះមកវះធ្លុះពោះឬវះជាដើមខ្វែង ឲ្យមានប្រវែង ៦ ឬ ៧ ធ្នាប់ រួចហើយទើបការកសំរេចជាខាងក្រោយ; ចួនកាលសាមីរូបការកខ្លួនឯងមិនទាន់ស្រេចហៅឲ្យអ្នកជំនួយមកជួយបង្ហើយទេ ។ ឯអ្នកជំនួយនោះត្រូវរើសតែបុគ្គលដែលស្និទ្ធស្នាលដូចយ៉ាងមាតា-បិតា ឬញាតិសាច់មិត្រសំឡាញ់ដែលជិតដិត ។ អ្នកជំនួយដែលបានជួយពិឃាតនេះទៀតសោត សឹងមានសេចក្ដីពេញចិត្តនឹងកិច្ចនោះជាទីបំផុត ទុកដូចជាអ្នកដែលបានជួយបំបួសកុលបុត្រសម្រាប់ពុទ្ធសាសនាយើង ។

កិច្ចនេះ សម្រាប់ធ្វើបានតែពួកអ្នកដែលយល់ឃើញថាសុចរិតផង, ចំណែកមនុស្សដែលមានទោសគួរដល់ពិឃាតជីវិតបង់ គេមិនព្រមឲ្យ

វិធីនេះទេ ត្រូវតែប្រហារជីវិតតាមច្បាប់រាជការ ។ សាសនានេះហើយដែលនាំឲ្យជាតិជប៉ុន មិនចេះរួញរានឹងសេចក្ដីស្លាប់ ។

សាសនាស៊ិន្តូ ជាសាសនាដើមរបស់ជប៉ុន, តែតមកខាងក្រោយព្រះពុទ្ធសាសនាផ្សាយចូលទៅដល់នាំឲ្យមនុស្សជ្រះថ្លាច្រើនជាង ហេតុដល់ក្លាយទៅសាសនាសម្រាប់រាជការផែនដីជំនួសកន្លែងស៊ិន្តូបាន ។

ព្រះពុទ្ធសាសនាផ្សាយចូលទៅប្រទេសជប៉ុនរវាង ព. ស. ១០៩៥ ដោយព្រះចៅផែនដីកៅហ្វីបានបញ្ជូនព្រះពុទ្ធរូបទៅថ្វាយព្រះបាទ គិម្មេ-ត្បី របស់ជប៉ុន, បន្ទាប់មកបានបញ្ជូនភិក្ខុឲ្យចូលទៅប្រកាសសាសនាក្នុងប្រទេសជប៉ុនទៀត ដរាបទាល់តែសម្បូរពុទ្ធសាសនិកនិកាយ ដល់ចំនួន ៤៨ លាននាក់ មានវត្តចំនួន ៧ ហ្មឺន, ឯសាសនាស៊ិន្តូមានចំនួនមនុស្សតែ ១៦ លានប៉ុណ្ណោះ ។

កាលបើព្រះពុទ្ធសាសនា ជាភ័យធំរបស់សាសនាស៊ិន្តូដូច្នេះហើយ អធិករណ៍ក៏កើតឡើងរវាងសាសនាទាំងពីរ, តែព្រះពុទ្ធសាសនាមានជ័យជំនះ គឺគេទុកជាសាសនាសម្រាប់ផែនដី ដរាបដល់មករាជ្យព្រះនាងឈុយកូ (ព. ស. ១១៣៦ - ១១៧១) ។

លុះដល់មករាជព្រះបាទមត្សុហិតូ (ព. ស. ២៤១០ - ២៤៥៥) ទើបប្រកាសផ្លាស់យកសាសនាស៊ិន្តូជាសាសនាសម្រាប់រាជការវិញ ដើម្បីឲ្យជនជាតិជប៉ុនមានលក្ខណៈជាជប៉ុនសុទ្ធ តាំងពីសាសនាសម្រាប់ជាតិផង ។

ចប់